កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

LUXEMBOURG
AID & DEVELOPMENT

Implemented by
giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# ធ្វើឱ្យប្រសើរឡើងដល់ការផ្ដល់សេវា ជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា

## សង្គមដែលមានបរិយាបន្ន និងសន្តិភាព















ក្នុងនាមជាសហគ្រាសរបស់រដ្ឋ GIZ គាំទ្ររដ្ឋាភិបាលអាល្លឺម៉ង់ដើម្បីសម្រេចគោលបំណងនៅក្នុងវិស័យ
សហប្រតិបត្តិការអន្តរជាតិដើម្បីការអភិវឌ្ឍប្រកបដោយនិរន្តរភាព។


**បោះពុម្ពផ្សាយដោយ**
Deutsche Gesellschaft für
Internationale Zusammenarbeit (GIZ) GmbH

ការិយាល័យកណ្ដាល
Bonn and Eschborn, ប្រទេសអាល្លឺម៉ង់

អាសយដ្ឋាន
ការិយាល័យកម្មវិធី ISD ភ្នំពេញ
អាគារសោយ័ណ្ណ លេខ៤២ ផ្លូវសម្ដេចប៉ាន (២១៤) សង្កាត់បឹងរាំង ខណ្ឌដូនពេញ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ +៨៥៥ ២៣ ២១ ៦៧ ៥៦
ទូរសារ +៨៥៥ ២៣ ២១ ២៧ ៨៣

អ៊ីមែល giz-kambodscha@giz.de
វេបសាយ www.giz.de/en


**អំពីកម្មវិធី**
កម្មវិធី "ធ្វើឱ្យប្រសើរឡើងដល់ការផ្ដល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា" ដែលហៅកាត់ជាភាសាអង់គ្លេសថា (ISD) គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ក្នុងវិស័យគ្រប់គ្រងសំរាម សំណល់រឹង ការគ្រប់គ្រងទឹក សេវាសុខាភិបាល សេវារដ្ឋបាល និងការធ្វើឱ្យប្រសើរឡើងដល់វិមជ្ឈការហិរញ្ញវត្ថុ។


**អ្នកទទួលខុសត្រូវ**
Friederike Burkert, ប្រធានគ្រប់គ្រងកម្មវិធី ISD, GIZ
អ៊ីមែល friederike.burkert@giz.de

**អត្ថបទដោយ**
នឹម សួរ ទីប្រឹក្សា ISD/GIZ
ឌី ឌីនណា ទីប្រឹក្សា ISD/GIZ
ប៊ិ សុភី ទីប្រឹក្សា ISD/GIZ
ឆាត ភារិត ទីប្រឹក្សា ISD/GIZ
ទីន សុវណ្ណធាន ទីប្រឹក្សា ISD/GIZ
ប៊ុន ថុល ទីប្រឹក្សា ISD/GIZ
សន សុផានី ទីប្រឹក្សា ISD/GIZ
សក់ សុធា ទីប្រឹក្សា ISD/GIZ
គង់ វណ្ណថាត ទីប្រឹក្សា ISD/GIZ
តាំង សុផាន់ណារ៉ា ទីប្រឹក្សា ISD/GFA
អង់ សុវណ្ណា ទីប្រឹក្សា ISD/GFA

**រចនាទំព័រដោយ**
ជឹម ចំរើន, អ្នកឯកទេសផ្នែកទំនាក់ទំនង, GIZ

**រូបថត**
ក្របសៀវភៅ៖ GIZ/នឹម សួរ, សោ សុខជា, ហួយ រិទ្ធីការ
GIZ/នឹម សួរ ទំព័រ ៣ ៤
GIZ/ឆាត ភារិត ទំព័រ ៥
GIZ/ពិន បូរី ទំព័រ ៧
GIZ/គង់ វណ្ណថាត ទំព័រ ៨ ៩ ១០
GIZ/ផន វុទ្ធី ទំព័រ ១១
សោ សុខជា ទំព័រ ១៥ ១៦ ១៧
តាំង សុផាន់ណារ៉ា ទំព័រ ១៨ ១៩
ធូ សោភ័ណ ទំព័រ ១៣
ហួយ រិទ្ធីការ ទំព័រ ១៤
លេខាធិការដ្ឋាន គ.ជ.អ.ប. ទំព័រ ២០ ២១



**ផែនទី**
ផែនទីដែលត្រូវបានប្រើប្រាស់នៅក្នុងឯកសារនេះគឺសម្រាប់ជាការផ្ដល់ព័ត៌មានប៉ុណ្ណោះ និងមិនមែនសម្គាល់ថាជាផែនទីដែលទទួលស្គាល់ដោយច្បាប់ឬសន្ធិសញ្ញាអន្តរជាតិស្ដីពីព្រំដែននិងដែនដីនោះទេ។ GIZ ពុំទទួលខុសត្រូវក្នុងការធានាថាផែនទីទាំងនេះ ត្រូវបានធ្វើបច្ចុប្បន្នភាព ត្រឹមត្រូវ ឬពេញលេញនោះទេ។ ពុំមានការទទួលខុសត្រូវណាមួយនឹងត្រូវបានអនុវត្តនោះឡើយ ចំពោះរាល់ការប៉ះពាល់ខូចខាត ដោយផ្ទាល់ក្ដី ឬដោយប្រយោលក្ដី ដែលកើតចេញពីការប្រើប្រាស់ផែនទីទាំងនេះ។



តាងនាម ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (BMZ)

ភ្នំពេញ ខែវិច្ឆិកា ឆ្នាំ២០២៥

# ធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវា ជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា

សង្គមដែលមានបរិយាបន្ន និងសន្តិភាព

# មាតិកា


អក្សរកាត់ ii

ទិដ្ឋភាពទូទៅនៃកម្មវិធី ១

ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងយន្តការបណ្តឹង ៣

ប្រែក្លាយបទពិសោធន៍សាកល្បងទៅជាគោលនយោបាយ៖ "ការដាក់ឱ្យអនុវត្តជាប្រព័ន្ធនូវការងារគណនេយ្យភាពសង្គម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ" ៥

ការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងអភិបាលកិច្ចប្រកបដោយបរិយាបន្ន ៧

ពង្រឹងសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ៩

វិមជ្ឈការហិរញ្ញវត្ថុ ១១

ការកែលម្អការផ្តល់សេវារដ្ឋបាលផ្តោតលើប្រជាពលរដ្ឋ ១៣

ការដោះស្រាយបញ្ហាគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយនិរន្តភាព៖ ការផ្តល់សិទ្ធអំណាចដល់សហគមន៍ និងរដ្ឋបាលមូលដ្ឋាន ១៥

យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងទឹក ១៨

ពីគោលនយោបាយ ទៅការអនុវត្ត៖ ការធ្វើមូលដ្ឋាននីយកម្មនៃការគ្រប់គ្រងវិស័យអប់រំតាមរយៈរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ២០

# អក្សរកាត់

| | |
|---|---|
| ADB | ធនាគារអភិវឌ្ឍអាស៊ី |
| API | ចំណុចតភ្ជាប់កម្មវិធី |
| BMZ | ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ |
| BoGs | គណៈអភិបាល |
| CAF | អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ |
| CamDX | ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា |
| CamDigiKey | ថ្នាល CamDigiKey (ប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល) |
| CP | ផែនការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន |
| CS-WMP | ផែនការគ្រប់គ្រងទឹក ដោយគិតពីបម្រែបម្រួលអាកាសធាតុ |
| D&D | វិមជ្ឈការ និងវិសហមជ្ឈការ |
| DFR | នាយកដ្ឋានមុខងារ និងធនធាន |
| DIP | កម្មវិធីវិនិយោគស្រុក |
| DM | ស្រុក និងក្រុង |
| DMK | ស្រុក ក្រុង និងខណ្ឌ |
| DO | ការិយាល័យប្រជាពលរដ្ឋ |
| FWUC | សហគមន៍កសិករប្រើប្រាស់ទឹក |
| GESEI | សមភាពយេនឌ័រ បរិយាបន្ននិង សមធម៌សង្គម |
| GIS | កម្មវិធីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| I4C | កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ |
| ISAF | ការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម |
| ISD | កម្មវិធី "ធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា" |
| JAAP | ផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម |
| JICA | ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន |
| MCS | ក្រសួងមុខងារសាធារណៈ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoI | ក្រសួងមហាផ្ទៃ |
| MoWA | ក្រសួងកិច្ចការនារី |
| MoWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| NASLA | សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| NCDDS | លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NP-2 | កម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) |
| OWSM | យន្តការច្រកចេញចូលតែមួយ |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ |
| PdWRAM | មន្ទីរធនធានទឹក និងឧត្តុនិយមខេត្ត |
| SA | គណនេយ្យភាពសង្គម |
| SDC | ទីភ្នាក់ងារស្វីសដើម្បីកិច្ចអភិវឌ្ឍ និងសហប្រតិបត្តិការ |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ToT | វគ្គបណ្តុះបណ្តាលគ្រូបង្គោល |
| UNDP | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| WMP | ផែនការគ្រប់គ្រងសំរាម សំណល់រឹង |
| WVI | អង្គការទស្សនៈពិភពលោកអន្តរជាតិ |

# ទិដ្ឋភាពទូទៅនៃកម្មវិធី

## សាវតា

កម្មវិធី "ធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា" ដែលហៅកាត់ជាភាសាអង់គ្លេសថា (ISD) គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយគុណភាព ក្នុងវិស័យគ្រប់ គ្រងសំរាម សំណល់រឹង ការគ្រប់គ្រងទឹក សេវាសុខាភិបាល សេវារដ្ឋបាល និងការធ្វើឱ្យប្រសើរឡើងដល់វិមជ្ឈការហិរញ្ញវត្ថុ ដែលអនុវត្តនៅខេត្តគោលដៅចំនួន០៣គឺ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។

កម្មវិធី ISD មានគោលបំណងធ្វើឱ្យរដ្ឋបាលក្រុង ស្រុកនៃខេត្តគោលដៅប្រើប្រាស់យុទ្ធសាស្ត្រ និងយន្តការនានាដែលមានលក្ខណៈល្អប្រសើរក្នុងការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋ។ កម្មវិធីនេះផ្តោតជាសំខាន់លើ (១)ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) ជាពិសេសក្នុងវិស័យសុខាភិបាល និងការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ ដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (២)ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធឌីជីថល និងចល័ត (៣)ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងសំរាម សំណល់រឹង និងគ្រប់គ្រងទឹក ដែលមានលក្ខណៈធន់នឹងការប្រែប្រួលអាកាសធាតុ និងអាចពង្រីកការអនុវត្តនៅរដ្ឋបាលក្រុង ស្រុកផ្សេងទៀតបាន (៤)ការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និងការពង្រឹងយន្តការគណនេយ្យភាពសង្គម និងការប្រើប្រាស់យន្តការទាំងនេះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការដោះស្រាយបណ្តឹងនៅថ្នាក់ស្រុក និងក្រុង និង (៥)ការធ្វើឱ្យប្រសើរឡើងហិរញ្ញវត្ថុមូលដ្ឋាន (ថ្នាក់ក្រុង ស្រុក)។

## វិធីសាស្ត្រ

កម្មវិធី ISD ប្រើប្រាស់ពហុវិធីសាស្ត្រនៅគ្រប់កម្រិតថ្នាក់ ដោយរួមបញ្ចូលគ្នា ទាំងការផ្តល់ប្រឹក្សាផ្នែកបច្ចេកទេស និងអំពីដំណើរការនៃការអនុវត្តការងារ ដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមរយៈការិយាល័យរបស់កម្មវិធី នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។

កម្មវិធីនេះ អនុវត្តការអភិវឌ្ឍសមត្ថភាពតាមបែបចម្រុះ ដោយធ្វើការបណ្តុះបណ្តាលកម្រិតបុគ្គល បញ្ចូលទៅក្នុងកិច្ចដំណើរការ និងនីតិវិធីរបស់ស្ថាប័ន។ ដូចនេះ ចំណេះដឹងជំនាញដែលទទួលបានថ្មីៗ គឺជាមូលដ្ឋានយ៉ាងសំខាន់ ក្នុងការប្រើប្រាស់សម្រាប់កិច្ចការងារប្រចាំថ្ងៃរបស់រដ្ឋបាលក្រុង ស្រុក និងសម្រាប់ការកែលម្អការងារនៅក្នុងរយៈពេលយូរខាងមុខ។ ការចូលរួមរបស់មន្ទីរជំនាញ និងអង្គភាពនានា នៅថ្នាក់ខេត្ត និងថ្នាក់ជាតិបានជួយគាំទ្រដល់ការផ្តល់សេវារបស់រដ្ឋបាលក្រុង ស្រុក ដែលនេះ




រូបទី១៖ ខេត្តគោលដៅរបស់កម្មវិធី

| | |
|---|---|
| ឈ្មោះកម្មវិធី | ធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា (ISD) |
| ផ្តល់ជំនួយដោយ | ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (BMZ)<br>ទីភ្នាក់ងារស្វីសដើម្បីកិច្ចអភិវឌ្ឍ និងសហប្រតិបត្តិការ (SDC)<br>រដ្ឋាភិបាល Luxembourg |
| ទីតាំងអនុវត្តគម្រោង | ប្រទេសកម្ពុជា (រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប) |
| ភ្នាក់ងារដឹកនាំប្រតិបត្តិ | លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប.) |
| រយៈពេល | ខែមីនា ឆ្នាំ២០២២ រហូតដល់ខែធ្នូ ឆ្នាំ២០២៥ |

ជាការបំពេញបន្ថែមនូវចំណេះដឹងដែលទទួលបានពីការអភិវឌ្ឍសមត្ថភាពកន្លងមក ដែលរួមមានទាំងការបណ្តុះបណ្តាលនៅកន្លែងធ្វើការ និងការប្រឹក្សាយោបល់ផងដែរ។ នៅថ្នាក់ក្រុង ស្រុក កម្មវិធី ISD បានគាំទ្រក្នុងការបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងសំរាម សំណល់រឹង ដែលនេះជាការបំពេញបន្ថែមដល់ការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងសំរាម សំណល់រឹង។ យន្តការនេះជួយពង្រឹងដល់កិច្ចសន្ទនា និងការធ្វើសេចក្តីសម្រេចនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលផ្តល់ផលប្រយោជន៍ ផ្ទាល់ដល់ប្រជាពលរដ្ឋ។ ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល នៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋធ្វើឱ្យប្រសើរឡើងដល់លទ្ធភាពនៃការទទួលបានព័ត៌មាន និងការទទួលបានសេវារដ្ឋបាល។

## ដៃគូអនុវត្ត

ភាគីពាក់ព័ន្ធសំខាន់ៗក្នុងការអនុវត្តកម្មវិធីរួមមាន៖

- **ថ្នាក់ជាតិ៖** លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋានគ.ជ.អ.ប.) ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ក្រសួងធនធានទឹកនិងឧតុនិយម។
- **ថ្នាក់ក្រោមជាតិ៖** រដ្ឋបាលខេត្ត ស្រុក ក្រុង ឃុំ សង្កាត់ និងការិយាល័យប្រជាពលរដ្ឋ។
- **សង្គមស៊ីវិល៖** វិស័យឯកជន អ្នកសម្របសម្រួលសហគមន៍នៃគម្រោងគណនេយ្យភាពសង្គម អង្គការមិនមែនរដ្ឋាភិបាល និងប្រជាពលរដ្ឋ។
- **ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍន៍៖** ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មូលនិធិកុមារអង្គការសហប្រជាជាតិ (UNICEF) នាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្ម (DFAT)។



↑ ការផ្សព្វផ្សាយអំពីតួនាទីរបស់ការិយាល័យប្រជាពលរដ្ឋនៅស្រុកមោងឫស្សី

# ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត និងយន្តការបណ្តឹង

កម្មវិធី ISD បានរួមចំណែកលើកកម្ពស់ការបំពេញការងាររបស់ការិយាល័យប្រជាពលរដ្ឋ ដោយសហការជាមួយនាយកដ្ឋានមុខងារ និងធនធាននៃក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការចូលរួមចំណែកនេះ គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យការឆ្លើយតប និងគណនេយ្យភាពក្នុងការផ្តល់សេវាសាធារណៈកាន់តែមានភាពប្រសើរឡើង។

## សមិទ្ធផលសំខាន់ៗ

**សមត្ថភាពបំពេញការងារត្រូវបានពង្រឹង និងការឆ្លើយតបត្រូវបានកែលម្អ៖** សមត្ថភាពបំពេញការងាររបស់ប្រធានការិយាល័យប្រជាពលរដ្ឋ ត្រូវបានពង្រឹង ដោយបានធ្វើឱ្យពួកគាត់មានសមត្ថភាពក្នុងការគ្រប់គ្រង និងឆ្លើយតបមតិយោបល់ របស់ប្រជាពលរដ្ឋក្នុងលក្ខណៈជាប្រព័ន្ធឆាប់រហ័ស និងកាន់តែមានប្រសិទ្ធភាពជាងមុន។ ការអភិវឌ្ឍសមត្ថភាពនេះបានគ្របដណ្តប់លើវិសាលភាពទូទាំងប្រទេស ដោយបានធ្វើឱ្យប្រធាន មន្ត្រីជំនួយការ និងមន្ត្រីពាក់ព័ន្ធដទៃទៀតនៃការិយាល័យប្រជាពលរដ្ឋ ចំនួន ១.៥២៦នាក់ ទទួលបានចំណេះដឹង និងជំនាញពាក់ព័ន្ធលិខិតបទដ្ឋានគតិយុត្ត ជំនាញអន្តរបុគ្គល និងចំណេះដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងទិន្នន័យបណ្តឹងតាមប្រព័ន្ធអនឡាញ ដែលត្រូវការចាំបាច់សម្រាប់ការគ្រប់គ្រងបណ្តឹង និងការឆ្លើយតបទៅនឹងបណ្តឹងឱ្យមានប្រសិទ្ធភាព។ តាមរយៈថេប្លេតដែលបានផ្តល់ជូន ប្រធានការិយាល័យប្រជាពលរដ្ឋ នៅក្នុងរដ្ឋបាលក្រុង ស្រុកដែលបានជ្រើសរើស បានបង្ហាញអំពីសមត្ថភាពកាន់តែប្រសើរ ក្នុងការឆ្លើយតបទៅនឹងមតិ យោបល់ត្រឡប់ និងការសាកសួរព័ត៌មាននានារបស់ប្រជាពលរដ្ឋ ដែលបានទទួលតាមប្រព័ន្ធអនឡាញ។ ការកើនឡើងផ្នែកចំណេះដឹង និងធនធាន បានជួយលើកកម្ពស់សមត្ថភាពជាទូទៅរបស់ការិយាល័យប្រជាពលរដ្ឋ ក្នុងការឆ្លើយតបទាន់ពេលវេលា និងមានប្រសិទ្ធភាព។

**ការយល់ដឹង និងការស្គាល់ការិយាល័យប្រជាពលរដ្ឋត្រូវបានលើកកម្ពស់៖** ផែនការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានសម្រាប់ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើប្រាស់ ដើម្បីផ្តល់ព័ត៌មានក្នុងលក្ខណៈជាប្រព័ន្ធជូនដល់សាធារណៈជន អំពីការិយាល័យប្រជាពលរដ្ឋ ។ ជាមួយគ្នានេះដែរ និមិត្តសញ្ញាសម្រាប់ការិយាល័យប្រជាពលរដ្ឋត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ដោយក្រសួងមហាផ្ទៃ។ ផែនការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន និងនិមិត្តសញ្ញាមានសារៈសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹង និងការកត់ចំណាំ(ស្គាល់) របស់ប្រជាពលរដ្ឋចំពោះ ការិយាល័យប្រជាពលរដ្ឋ ក៏ដូចជាលើកកម្ពស់ដល់ការចូលរួមរបស់សាធារណជន។ ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងដែលបានរៀបចំនៅតាមសាកលវិទ្យាល័យនានា មានការចូលរួមពីនិស្សិតសរុបចំនួន ៧៨៦ នាក់ (៦៥% ជាស្រី) ដែលនាំឱ្យចំនួននៃការសាកសួរព័ត៌មានអំពីសេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការិយាល័យប្រជាពលរដ្ឋ មានការកើនឡើង។

**ការចូលរួមរបស់ប្រជាពលរដ្ឋ តាមរយៈប្រព័ន្ធផ្តល់មតិត្រឡប់តាមប្រព័ន្ធអនឡាញមានការកើនឡើង៖** កម្មវិធីទូរស័ព្ទដៃ "**មតិយើង**" ដែលត្រូវបានដាក់ឱ្យអនុវត្តសាកល្បង ដោយកម្មវិធី ISD នៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានជ្រើសរើស បានផ្តល់ឱកាសឱ្យប្រជាពលរដ្ឋប្រហែល ៣,៣ លាននាក់ ក្នុងការផ្តល់មតិត្រឡប់ និងស្នើសុំការជួយសម្របសម្រួលពីការិយាល័យប្រជាពលរដ្ឋដោយផ្ទាល់។ គិតចាប់ពីចុងឆ្នាំ ២០២៣ ដល់ចុងឆ្នាំ២០២៤ កម្មវិធីទូរស័ព្ទដៃត្រូវបានទាញយកចំនួន ៨,១៧៧ដង និងទទួលបានមតិត្រឡប់ និងការសាកសួរព័ត៌មានអំពីសេវាចំនួន ១០៨ករណី។

**ការទទួលយកដើម្បីកែលម្អសេវាសាធារណៈ៖** នៅចន្លោះពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៤ ការិយាល័យប្រជាពលរដ្ឋ នៃរដ្ឋបាលក្រុង ស្រុក នៃខេត្តដៃគូរបស់កម្មវិធី ISD បានទទួល



↑ សិក្ខាសាលាឆ្លុះបញ្ចាំងអំពីតួនាទីរបស់ការិយាល័យប្រជាពលរដ្ឋ



↑ ការផ្សព្វផ្សាយអំពីតួនាទីរបស់ការិយាល័យប្រជាពលរដ្ឋនៅសាកលវិទ្យាល័យ

បណ្ដឹងតវ៉ា និងបានលើកជារបាយការណ៍ជូនរដ្ឋបាលក្រុង ស្រុក ចំនួន ១៥៦ ករណី ក្នុងចំណោមនោះ មាន១៣[1] ករណី ត្រូវបានលើកយកទៅពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងដោះស្រាយដើម្បីកែលម្អសេវា។ ការណ៍នេះបង្ហាញអំពីវិវឌ្ឍន៍ដ៏សំខាន់ផ្នែកគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ដំណើរការសំខាន់ៗ

**ការកំណត់តម្រូវការអភិវឌ្ឍន៍សមត្ថភាព និងការឯកភាពលើកិច្ចអន្តរាគមន៍នានាដើម្បីឆ្លើយតប៖** ដំបូងធ្វើការវិភាគអំពីតួនាទី មុខងារ និងសិទ្ធិអំណាចរបស់ការិយាល័យប្រជាពលរដ្ឋ ហើយវាយតម្លៃសមត្ថភាពរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ តាមរយៈវគ្គប្រឹក្សាយោបល់ ទើបកំណត់បាននូវតម្រូវការអភិវឌ្ឍន៍សមត្ថភាព រាប់បញ្ចូលទាំងតម្រូវការធនធាន។ ផ្អែកលើតម្រូវការអភិវឌ្ឍសមត្ថភាពដែលកំណត់បាន រៀបចំសិក្ខាសាលាបណ្ដុះបណ្ដាល សិក្ខាសាលាឆ្លុះបញ្ចាំង និងផ្លាស់ប្ដូរបទពិសោធន៍ដើម្បីពង្រឹងសមត្ថភាពទាំងកម្រិតបុគ្គល និងកម្រិតស្ថាប័ន។

**ការកំណត់រកវិធីសាស្ត្រ ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់ភាគីពាក់ព័ន្ធ៖** ភាគីពាក់ព័ន្ធត្រូវបានពិគ្រោះយោបល់អំពីវិធីសាស្ត្រសម្រាប់លើកកម្ពស់ការយល់ដឹង ហើយបានរួមគ្នាបង្កើតជាជម្រើសផ្សេងៗ និងបានឯកភាពទៅលើជម្រើសសមស្រប ដូចជាការរៀបចំជាផែនការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន និងនិមិត្តសញ្ញាសម្រាប់ការិយាល័យប្រជាពលរដ្ឋ ហើយត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

**ការបង្កើតយន្តការឌីជីថល សម្រាប់ប្រជាពលរដ្ឋផ្ដល់មតិត្រឡប់ និងសាកសួរព័ត៌មាន៖** កម្មវិធី ISD បានសហការជាមួយដៃគូដាក់ឱ្យអនុវត្តសាកល្បងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ "មតិយើង"។ កម្មវិធីទូរស័ព្ទនេះគឺសម្រាប់ឱ្យប្រជាពលរដ្ឋផ្ដល់មតិត្រឡប់ និងការសាកសួរព័ត៌មានអំពីសេវារដ្ឋបាលតាមអនឡាញ។ កម្មវិធីទូរស័ព្ទដៃនេះ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដើម្បីលើកកម្ពស់ការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមករវាងប្រជាពលរដ្ឋ និងប្រធានការិយាល័យប្រជាពលរដ្ឋ។

**ការចូលរួមរបស់ថ្នាក់ដឹកនាំ នៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការដោះស្រាយមតិត្រឡប់៖** ការលើកកម្ពស់ការយល់ដឹងរបស់អ្នកធ្វើសេចក្ដីសម្រេចចិត្តអំពីតួនាទី ភារកិច្ចរបស់គាត់ និងការផ្ដល់ព័ត៌មានដែលមានមូលដ្ឋានច្បាស់លាស់ និងទាន់ពេលវេលា តាមរយៈរបាយការណ៍ជាទៀងទាត់ បង្កលក្ខណៈឱ្យអ្នកធ្វើសេចក្ដីសម្រេចចិត្ត មានសមត្ថភាពពេញលេញក្នុងការឆ្លើយតបទៅនឹងមតិត្រឡប់របស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព។

**ការសិក្សាវាយតម្លៃ ដើម្បីកែលម្អការបំពេញការងាររបស់ការិយាល័យប្រជាពលរដ្ឋ៖** ការសិក្សានេះត្រូវបានធ្វើឡើងដើម្បីវាយតម្លៃការបំពេញការងាររបស់ការិយាល័យប្រជាពលរដ្ឋ និងធ្វើការប្រៀបធៀបជាមួយការអនុវត្តល្អៗក្នុងប្រទេសក្នុងតំបន់ និងអន្តរជាតិ ក៏ដូចជា ប្រៀបធៀបនឹងស្ថាប័នរបស់រដ្ឋាភិបាលផ្សេងទៀត។ ការសិក្សានេះមានគោលបំណងរកឱ្យឃើញនូវចំណុចខ្វះខាតសម្រាប់កែលម្អ។

## និរន្តរភាព

ការបង្កើតបណ្ដាញសម្រាប់ចែករំលែកចំណេះដឹង ក្នុងចំណោមប្រធានការិយាល័យប្រជាពលរដ្ឋ ក្នុងខេត្តគោលដៅ ដូចជា ក្រុមតេលេក្រាម គឺបង្កលក្ខណៈឱ្យមានការចែករំលែកចំណេះដឹងបន្តទៀត ហើយធានាបាននូវនិរន្តរភាពនៃការអនុវត្ត និងចែករំលែកបទពិសោធន៍ល្អៗ។

សមិទ្ធផលមួយចំនួន រួមមាន ផែនការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន និងនិមិត្តសញ្ញាសម្រាប់ការិយាល័យប្រជាពលរដ្ឋ ត្រូវបានរៀបចំធ្វើរួមគ្នាជាមួយដៃគូ។ និមិត្តសញ្ញាសម្រាប់ការិយាល័យប្រជាពលរដ្ឋ ត្រូវបានដាក់បង្ហាញឱ្យឃើញយ៉ាងច្បាស់នៅលើបដា ផ្ទាំងផ្សព្វផ្សាយ ខិត្តបណ្ណ សំបុត្រឆ្លើយឆ្លងរបស់ការិយាល័យប្រជាពលរដ្ឋ និងនៅលើឯកសណ្ឋានរបស់ប្រធានការិយាល័យប្រជាពលរដ្ឋ។ ការប្រើប្រាស់និមិត្តសញ្ញាបែបនេះ ធ្វើឱ្យជាប់បានយូរ និងលើកកម្ពស់ភាពងាយឃើញ និងភាពស្គាល់ចំណាំបាន។

កម្មវិធីទូរស័ព្ទសម្រាប់ទទួលមតិត្រឡប់ពីប្រជាពលរដ្ឋត្រូវបានយកប្រើ ហើយបានបញ្ចូលក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ខ្លួន និងបានដាក់ឱ្យដំណើរការរួមគ្នាជាមួយប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្ដឹងអនឡាញរបស់ដៃគូផងដែរ។

1 ពាក្យបណ្ដឹងខ្លះមានលក្ខណៈសាមញ្ញ ឬជាសំណូមពរ ដែលប្រធានការិយាល័យប្រជាពលរដ្ឋអាចដោះស្រាយជូនប្រជាពលរដ្ឋដោយផ្ទាល់ ដោយមិនចាំបាច់ត្រូវយកទៅពិភាក្សាក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។



↑ កិច្ចប្រជុំរវាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងការិយាល័យប្រជាពលរដ្ឋអំពីការរៀបចំកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ

# ប្រែក្លាយបទពិសោធន៍សាកល្បងទៅជាគោលនយោបាយ៖ "ការដាក់ឱ្យអនុវត្តជាប្រព័ន្ធនូវការងារគណនេយ្យភាពសង្គមនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ"

## សាវតារ

រាជរដ្ឋាភិបាលកម្ពុជា មានការតាំងចិត្តខ្ពស់ក្នុងការដាក់ឱ្យអនុវត្តជាប្រព័ន្ធនូវការងារគណនេយ្យភាពសង្គម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ដើម្បីធានាបាននូវនិរន្តរភាពនៃការចូលរួមរបស់ប្រជាពលរដ្ឋ។

កម្មវិធី ISD សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. និងអង្គការទស្សនៈពិភពលោកអន្តរជាតិ (WVI) កំពុងសាកល្បងការដាក់ឱ្យប្រើប្រាស់ជាប្រព័ន្ធនូវការងារគណនេយ្យភាពសង្គមនៅក្នុងស្រុកព្រះនេត្រព្រះ និងស្រុកសង្កែ ដោយផ្តោតលើការិយាល័យច្រកចេញចូលតែមួយ និងវិស័យថ្មីចំនួនពីរ (ការគ្រប់គ្រងសំរាមសំណល់រឹង និងការគ្រប់គ្រងទឹក)។ ការសាកល្បងនេះមានគោលបំណងចងក្រងបទពិសោធន៍នៃការអនុវត្តជាក់ស្តែង និងយន្តការសំខាន់ៗនានាពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គមនៅស្រុកសាកល្បងដៃគូទាំងពីរ ដែលអាចបញ្ចូលទៅក្នុងវដ្ត និងជំហាននានាក្នុងការអនុវត្តការងារគណនេយ្យភាពសង្គមដែលមានស្រាប់ ដែលជាកត្តាជួយឱ្យមាននិរន្តរភាព នៃការអនុវត្តគណនេយ្យភាពសង្គមនៅរដ្ឋបាល ក្រុង ស្រុក ខណ្ឌ។

## សមិទ្ធផលសំខាន់ៗ

**ការពង្រឹងការអនុវត្តជាប្រព័ន្ធនូវការងារគណនេយ្យភាពសង្គម តាមរយៈការអនុវត្តសាកល្បង៖** ការអនុវត្តសាកល្បងនូវកិច្ចសហការ រវាងប្រធានការិយាល័យប្រជាពលរដ្ឋ និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ បានពង្រឹងការអនុវត្តការងារគណនេយ្យភាពសង្គម នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយបានធ្វើឱ្យប្រសើរឡើង នូវការសម្របសម្រួលរវាងតួអង្គពាក់ព័ន្ធនានា និងបង្កើនការកត់ចំណាំ (ស្គាល់) និងប្រសិទ្ធភាពនៃការអនុវត្តការងារគណនេយ្យភាពសង្គម។

អ្នកផ្តល់សេវា កាន់តែមានភាពឆ្លើយតបទៅនឹងអាទិភាពរបស់ប្រជាពលរដ្ឋ ដែលធ្វើឱ្យការចូលរួមរបស់ប្រជាពលរដ្ឋ កាន់តែកើនឡើង។ ក្នុងចំណោមប្រជាពលរដ្ឋចំនួន ១.៣៨៦នាក់ ដែលទទួលបានការផ្សព្វផ្សាយអំពីសកម្មភាពគណនេយ្យភាពសង្គម ប្រជាពលរដ្ឋជាង ៦០% បានដាក់សំណើ ឬមតិកែលម្អ ដែលបង្ហាញពីទំនុកចិត្តខ្លាំងរបស់សាធារណជន និងឆន្ទៈរបស់ពួកគាត់ក្នុងការចូលរួម។ សំណើភាគច្រើន ផ្តោតលើសេវាកម្មសំខាន់ៗ ដូចជា ហេដ្ឋារចនាសម្ព័ន្ធ អនាម័យ ការគ្រប់គ្រងបរិស្ថាន ការផ្តល់សេវា និងម៉ោងធ្វើការរបស់ការិយាល័យច្រកចេញចូលតែមួយ ការមានបង្គន់ប្រើប្រាស់ និងភាពស្អាត (សម្រាប់បុរស ស្ត្រី និងជនពិការ) ការគ្រប់គ្រងសំរាម សំណល់រឹង ទឹកស្អាត សុវត្ថិភាពភូមិ និងឃុំ ឱកាសសេដ្ឋកិច្ច និងការថែទាំប្រឡាយ។

ផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម (JAAP) ដែលរួមបញ្ចូលទាំងសេវាច្រកចេញចូលតែមួយ និងសេវាគ្រប់គ្រងសំរាម សំណល់រឹង ត្រូវបានបន្សី និងបញ្ចូលទៅក្នុងកម្មវិធីវិនិយោគស្រុក (DIP) ដោយជោគជ័យ ដែលជាកត្តារួមចំណែកឱ្យការធ្វើផែនការមានភាពឆ្លើយតបជាងមុន និងការផ្តល់សេវាដល់ប្រជាពលរដ្ឋនៅមូលដ្ឋានកាន់តែប្រសើរឡើង។

ជំហានសំខាន់ៗក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ត្រូវបានធ្វើបច្ចុប្បន្នភាពស្របតាមបរិបទការងាររដ្ឋបាលក្រុង ស្រុក ចំណែកផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម ត្រូវបានរៀបចំទាន់ពេលវេលា និងបានដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគស្រុក តាមរយៈការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការល្អរវាងប្រធានការិយាល័យប្រជាពលរដ្ឋ និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

ការអភិវឌ្ឍសមត្ថភាពដល់ភាគីពាក់ព័ន្ធ បានពង្រឹងការយល់ដឹងរួមគ្នា អំពីតួនាទីផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការក្នុងចំណោមប្រធានការិយាល័យប្រជាពលរដ្ឋ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងរដ្ឋបាលក្រុង ស្រុក។

ប្រធានការិយាល័យប្រជាពលរដ្ឋ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការភ្ជាប់ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងរដ្ឋបាលក្រុង ស្រុក ក្នុងការពាំនាំសម្លេង និងបញ្ហារបស់ប្រជាពលរដ្ឋទៅដល់អ្នកសម្រេចចិត្ត ដើម្បីធ្វើការឆ្លើយតបទាន់ពេលវេលា។

ការទទួលខុសត្រូវរួមគ្នារបស់ប្រធានការិយាល័យប្រជាពលរដ្ឋ និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ បានធ្វើឱ្យការសម្របសម្រួល កាន់តែមានភាពរលូន ក្នុងដំណើរការរៀបចំកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ការដាក់ពិន្ទុសហគមន៍ និងការបង្កើតផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម។ បទពិសោធន៍នេះ បាននាំមកនូវយន្តការដ៏រឹងមាំមួយ ក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម និងការផ្តល់សេវាកាន់តែឆ្លើយតប។

**ការរៀបចំគោលនយោបាយ និងការបញ្ចូលវិស័យថ្មី (ការគ្រប់គ្រងសំរាម សំណល់រឹង និងការគ្រប់គ្រងទឹក) ទៅក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម៖** សូចនាករ លក្ខណៈវិនិច្ឆ័យ ដំណើរការរៀបចំកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ (I4C) ដំណើរការរៀបចំប័ណ្ណពិន្ទុសហគមន៍ និងកម្មវិធីសិក្សាបណ្តុះបណ្តាលសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹង និងគ្រប់គ្រងទឹក រួមជាមួយនឹងមេរៀនបទពិសោធន៍ពីការសាកល្បងក្នុងស្រុកដៃគូទាំងពីរ ត្រូវបានបញ្ចូលទៅក្នុងសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមសម្រាប់ការអនុម័តដាក់ឱ្យប្រើប្រាស់ក្នុងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទូទាំងប្រទេស។ សៀវភៅណែនាំស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គមនេះ លើកកម្ពស់ឱ្យមានស្តង់ដាររួមមួយ និងពង្រឹងវប្បធម៌នៃការឆ្លើយតប និងការទទួលខុសត្រូវរួមគ្នារវាងប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋាន។

**អនុសាសន៍ស្តីពីការធ្វើសុខដុមនីយកម្មប្រព័ន្ធឌីជីថល៖** ការវាយតម្លៃដំណើរការនៃកម្មវិធីទូរស័ព្ទដៃចំនួនបី រួមមាន គណនេយ្យភាពសង្គម មតិយើង និងយន្តការច្រកចេញចូលតែមួយ (OWSM Cambodia) បានផ្តល់ផ្លូវច្បាស់លាស់សម្រាប់ប្រព័ន្ធអេកូឡូស៊ីឌីជីថល សម្រាប់ការងារគណនេយ្យភាពសង្គមដោយផ្តោតលើប្រជាពលរដ្ឋ។ ដើម្បីសម្រេចបាននូវគោលដៅនេះ ការវាយតម្លៃនេះ បានកំណត់បញ្ហាប្រឈមមួយចំនួន ពាក់ព័ន្ធនឹងភាពដោយឡែកពីគ្នានៃកម្មវិធីទាំង៣ និងផ្តល់យោបល់ក្នុងការធ្វើឱ្យប្រសើរឡើងដល់ដំណើរការប្រព័ន្ធឌីជីថលដែលគាំទ្រដោយបទពិសោធន៍របស់អ្នកប្រើប្រាស់ថ្នាលឌីជីថល ទម្រង់ឌីជីថល និងការឯកភាពរួមគ្នាមួយក្នុងការធ្វើសុខដុមនីយកម្មនៃកម្មវិធីទាំងបី។ ការពិនិត្យឡើងវិញផ្នែកបច្ចេកទេស បានណែនាំបន្ថែមទៀតអំពីការផ្លាស់ប្តូរឆ្ពោះទៅរកស្ថាបត្យកម្មប្រព័ន្ធទំនើបដោយប្រើសេវាកម្មខ្នាតតូច អន្តរប្រតិបត្តិការផ្អែកលើ API និងការបន្សីជាមួយវេទិកាជាតិដូចជា CamDX, CamDigiKey និងប្រព័ន្ធយោបល់ត្រលប់ដែលគ្រប់គ្រងដោយរដ្ឋាភិបាល។ ការវាយតម្លៃក៏បានស្នើឱ្យផ្លាស់ប្តូរឧបករណ៍ I4C ដែលមានស្រាប់ទៅជាឧបករណ៍ចល័តជាងមុន និងទំនើបជាងមុន (ប្រព័ន្ធផ្សព្វផ្សាយសង្គម) ដើម្បីបង្កើនភាពងាយស្រួល ក្នុងការទទួលបាន និងការចូលរួមរបស់ប្រជាពលរដ្ឋតាមប្រព័ន្ធឌីជីថល។

## ដំណើរការសំខាន់ៗ

**ដំណើរការអនុវត្តគណនេយ្យភាពសង្គមប្រកបដោយនិរន្តរភាព (ផ្អែកតាមក្របខ័ណ្ឌដែលមានស្រាប់)**



វដ្តគណនេយ្យភាពសង្គមដែលមានស្រាប់

## និរន្តរភាព

ការអនុវត្តសាកល្បងរបស់កម្មវិធី ISD បង្ហាញថា ការងារគណនេយ្យភាពសង្គម អាចដាក់ឱ្យអនុវត្តជាប្រព័ន្ធបាននៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ប្រកបដោយប្រសិទ្ធភាព នៅពេលដែលផ្អែកផ្គត់ផ្គង់ និងផ្អែកតម្រូវការធ្វើការរួមគ្នាតាមរយៈដំណើរការ ដែលមានលក្ខណៈជាប្រព័ន្ធ និងផ្អែកលើភស្តុតាងជាក់ស្តែង។ ដើម្បីធ្វើឱ្យការងារគណនេយ្យភាពសង្គម អាចអនុវត្តបាន ការពង្រឹងទំនុកចិត្តរបស់ប្រជាពលរដ្ឋ ព្រមទាំងការផ្តល់ឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ នូវឧបករណ៍ ប្រព័ន្ធ ការងារ និងសមត្ថភាពដែលចាំបាច់ជាកត្តាសំខាន់ ដើម្បីឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ អាចរក្សាគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារគណនេយ្យភាពសង្គម ដោយផុសចេញពីខ្លួនឯង និងមិនពឹងផ្អែកខ្លាំងលើការគាំទ្រពីខាងក្រៅ។



↑ វគ្គបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាស្ត្រីអំពីការនិយាយជាសាធារណៈ

# ការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងអភិបាលកិច្ចប្រកបដោយបរិយាបន្ន

## សមិទ្ធផលសំខាន់ៗ

កម្មវិធី ISD បានសម្រេចនូវវឌ្ឍនភាពសំខាន់ៗក្នុងការលើកកម្ពស់សមភាពយេនឌ័រ បរិយាបន្ននិង សមធម៌សង្គម (GESEI) ហើយក៏បានជំរុញលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី នៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បានពង្រឹងដល់ក្របខ័ណ្ឌស្ថាប័ន បានលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងបានបង្កើតយន្តការនិរន្តរភាព សម្រាប់ជំរុញដល់អភិបាលកិច្ច ដែលឆ្លើយតបនឹងយេនឌ័រនៅគ្រប់កម្រិតនៃការគ្រប់គ្រងរដ្ឋបាល។

ពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព **កម្មវិធីភាពជាអ្នកដឹកនាំ** ដែលមានរយៈពេល០៩ខែ បានផ្តល់ការបំពាក់បំប៉ននូវជំនាញចាំបាច់នានាក្នុងការដឹកនាំ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល ការបង្វឹកជាក្រុម និងបង្វឹកជាលក្ខណៈបុគ្គលដល់ស្ត្រី ដែលមានសក្តានុពលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងចំណោមស្ត្រី១២រូប ដែលបានចូលរួម មានស្ត្រីមួយចំនួនត្រូវបានតម្លើងឋានន្តរសក្តិ និងមួយចំនួនទៀតមានសក្តានុពល សម្រាប់ការតម្លើងឋានន្តរសក្តិក្នុងតួនាទីជាអ្នកដឹកនាំ។

**ការផ្តល់ភាពអង់អាចដល់ស្ត្រីដើម្បីដឹកនាំ - ការពង្រឹងសមត្ថភាពស្ត្រីក្នុងភាពជាអ្នកដឹកនាំ៖** តាមរយៈការបណ្តុះបណ្តាល ដើម្បីបង្កើនទំនុកចិត្ត ជំនាញ និងការចូលរួមក្នុងការធ្វើសេចក្តីសម្រេច ក្រុមប្រឹក្សា និងមន្ត្រីរាជការស៊ីវិលជាស្ត្រីជាង១០០ នាក់នៅក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តសៀមរាប បានពង្រឹងជំនាញពាក់ព័ន្ធនឹងភាពជាអ្នកដឹកនាំ ការសម្របសម្រួល ការដោះស្រាយវិវាទ និងការតស៊ូមតិ។ ក្នុងឆ្នាំ២០២៤ ការបណ្តុះបណ្តាលអំពី GESEI ត្រូវបានផ្តល់ជូនដល់គណៈអភិបាល នាយក និងនាយករងរដ្ឋបាលទាំងបុរស និងស្ត្រីចំនួន ១១៣ នាក់ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើន និងពង្រឹងជំនាញភាពជាអ្នកដឹកនាំប្រកបដោយបរិយាបន្ន និងការសម្រេចចិត្តដែលឆ្លើយតបទៅនឹងយេនឌ័រ។ នៅឆ្នាំ២០២៥ កម្មវិធីបានរៀបចំឱ្យមានការបណ្តុះបណ្តាលគ្រូបង្គោល (TOT) ស្តីពី GESEI ទាំងកម្រិតថ្នាក់ជាតិ និងក្រោមជាតិ។ មេរៀន និងឯកសារបណ្តុះបណ្តាល ត្រូវបានធ្វើបច្ចុប្បន្នភាពរួមគ្នាជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដូចជា៖ ក្រសួងកិច្ចការនារី សាលាជាតិរដ្ឋបាលមូលដ្ឋាន និងក្រុមការងារយេនឌ័រនៃក្រសួងមហាផ្ទៃ លេខាធិការដ្ឋានគ.ជ.អ.ប. និងក្រសួងមុខងារសាធារណៈ ហើយបានប្រគល់ឯកសារបណ្តុះបណ្តាលនេះ ជូនដល់សាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីបណ្តុះបណ្តាលស្តង់ដាររបស់ខ្លួន។

សមិទ្ធផលសំខាន់មួយទៀត គឺ**ផែនការយុទ្ធសាស្ត្រ ស្តីពីការបង្កើនចំនួនស្ត្រី ក្នុងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** (២០២៤-២០២៨) ដែលបានដាក់ឱ្យអនុវត្តតាមរយៈប្រកាសអន្តរក្រសួងរួមមាន៖ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងក្រសួងកិច្ចការនារី កាលពីដើមឆ្នាំ២០២៥។

↓ វគ្គបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាស្ត្រីនៅខេត្តសៀមរាប



ផែនការយុទ្ធសាស្ត្រនេះ បានផ្តល់នូវក្របខ័ណ្ឌរួម និងគោលការណ៍ណែនាំជាក់ស្តែង ដើម្បីពង្រឹងភាពតំណាងជាស្ត្រី និងលើកកម្ពស់ឱ្យមានប្រព័ន្ធដែលឆ្លើយតបនឹងយេនឌ័រ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

សមិទ្ធផលរួមគ្នាទាំងនេះ បាននាំឱ្យមាន ក្របខ័ណ្ឌស្ថាប័នកាន់តែរឹងមាំ ការពង្រឹងសមត្ថភាពភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការដាក់បញ្ចូលគោលការណ៍សមភាពយេនឌ័រទៅក្នុងរចនាសម្ព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ។

## ដំណើរការសំខាន់ៗ

**ភាពជាដៃគូសហការ៖** កម្មវិធី ISD ធានានូវកិច្ចសហការក្នុងចំណោមក្រសួង និងស្ថាប័នពាក់ព័ន្ធ រួមមានលេខាធិការដ្ឋានគ.ជ.អ.ប. សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងកិច្ចការនារី ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃ។ កិច្ចសហការនេះបានធានានូវភាពជាម្ចាស់ដ៏រឹងមាំ និងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (កជទី២) និងក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល។

**ការអភិវឌ្ឍសមត្ថភាព៖** កម្មវិធីនេះរួមបញ្ចូលគ្នានូវការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ ការរៀនសូត្រពីគ្នាទៅវិញទៅមក ការបង្វឹក និងការបណ្តុះបណ្តាល GESEI ដើម្បីបង្កើនសមត្ថភាពបុគ្គល និងស្ថាប័នក្នុងពេលដំណាលគ្នា។

**ការផ្សារភ្ជាប់គោលនយោបាយ និងការអនុវត្ត៖** បទពិសោធន៍ដែលទទួលបានពីកម្មវិធីបណ្តុះបណ្តាល បានរួមចំណែកយ៉ាងសំខាន់ក្នុងការរៀបចំសេចក្តីណែនាំ ស្តីពីការបង្កើនចំនួនស្ត្រី ក្នុងមុខតំណែងគ្រប់គ្រង និងលើកកម្ពស់បរិយាកាស និងលក្ខខណ្ឌអំណោយផលសម្រាប់ស្ត្រីនៅកន្លែងធ្វើការ និងក្នុងការអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន។

**វិធីសាស្ត្រប្រកបដោយបរិយាបន្ន និង សុវត្ថិភាព៖** គោលការណ៍ "មិនទុកនរណាម្នាក់ឱ្យនៅឯកោ" ការបង្កា និងការទប់ស្កាត់លើការបៀតបៀតផ្លូវភេទ និងការរើសអើងគ្រប់ទម្រង់ ត្រូវបានដាក់បញ្ចូលទៅគ្រប់សកម្មភាពទាំងអស់ ដើម្បីធានាដល់បរិយាបន្ន និងសុវត្ថិភាព។

## និរន្តរភាព

**ស្ថាប័នបណ្តុះបណ្តាល៖** ឯកសារបណ្តុះបណ្តាល GESEI ត្រូវបានប្រគល់ទៅស្ថាប័នបណ្តុះបណ្តាល សាលាជាតិរដ្ឋបាលមូលដ្ឋាន ជាផ្លូវការ ដើម្បីធានាឱ្យមានការផ្តល់វគ្គបណ្តុះបណ្តាលទៅតាមកម្មវិធីជាទៀងទាត់របស់ស្ថាប័ន។

**ក្របខ័ណ្ឌគោលនយោបាយ៖** ប្រកាសអន្តរក្រសួងស្តីពីផែនការយុទ្ធសាស្ត្រ (២០២៤-២០២៨) ផ្តល់នូវការតាំងចិត្តផ្នែកនយោបាយរយៈពេលវែង និងគណនេយ្យភាពសម្រាប់ការបង្កើនចំនួនស្ត្រីក្នុងភាពជាអ្នកដឹកនាំ។

**ការផ្ទេរសមត្ថភាព៖** វគ្គបណ្តុះបណ្តាលគ្រូបង្គោលលើប្រធានបទ GESEI នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានបង្កើតក្រុមគ្រូបង្គោល ដែលមានជំនាញសម្របសម្រួល ដែលអាចបន្តផ្តល់ការបណ្តុះបណ្តាលដែលឆ្លើយតបនឹងយេនឌ័រ ក្នុងពេលក្រោយៗទៀតបន្ទាប់ពីកម្មវិធី ISD ត្រូវបានបញ្ចប់។

**ការពង្រឹងបណ្តាញ៖** បណ្តាញក្រុម ស្ត្រីជាអ្នកដឹកនាំដែលបានទទួល ការបណ្តុះបណ្តាល និងអ្នកបង្ហាត់បង្ហាញនៅថ្នាក់ក្រោមជាតិ ដែលកាន់តែរីកធំធាត់ គាំទ្រឱ្យមានការរៀនសូត្រចែករំលែកបទពិសោធន៍រវាងគ្នាទៅវិញទៅមក និងការតស៊ូមតិដើម្បីនិរន្តរភាពនៃសមភាពយេនឌ័រ។

↓ កិច្ចប្រជុំក្រុមប្រឹក្សាស្រុកសូទ្រនិគម





↑ សមាជិកក្រុមប្រឹក្សាចូលរួមសិក្ខាសាលាផ្សព្វផ្សាយអំពីការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក

# ពង្រឹងសមត្ថភាពក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈ ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក

## សមិទ្ធផលសំខាន់ៗ

គំនិតផ្តួចផ្តើម ក្នុងការបង្កើតកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក មានគោលបំណងពង្រឹងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន តាមរយៈការពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលទើបជាប់ឆ្នោតថ្មី ក្នុងការបំពេញតួនាទី និងភារកិច្ច ស្របតាមអណត្តិរបស់ខ្លួន និងឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានប្រកបដោយប្រសិទ្ធភាព។

ដោយមានការសហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) កម្មវិធី ISD បានរៀបចំបង្កើតឯកសារបណ្តុះបណ្តាលចំនួន៥ម៉ូឌុលសំខាន់ៗ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។ រដ្ឋបាលក្រុង ស្រុក ចំនួន១០ បានបង្កើតមណ្ឌលស្វ័យសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ដើម្បីបង្កភាពងាយស្រួលដល់ក្រុមប្រឹក្សាក្នុងការចូលរួមវគ្គសិក្សានេះ។ សមាជិកក្រុមប្រឹក្សាសរុបចំនួន ២២០រូប (ស្ត្រី៤២រូប) បានចុះឈ្មោះចូលរៀនវគ្គសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ហើយសមាជិកក្រុមប្រឹក្សាចំនួន ១៦៩រូប ដែលរួមមានក្រុមប្រឹក្សាស្ត្រីទាំង៤២រូប បានបញ្ចប់វគ្គបណ្តុះបណ្តាល និងទទួលបានវិញ្ញាបនបត្រដោយជោគជ័យ។

លទ្ធផលនៃការវាយតម្លៃ និងការស្ទង់មតិកែលម្អ បានបង្ហាញពីការកើនឡើងគួរឱ្យកត់សម្គាល់ នូវចំណេះដឹង ទំនុកចិត្ត និងការយល់ដឹងកាន់តែច្បាស់ អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា ក្នុងការបំពេញភារកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាក៏បានបង្ហាញផងដែរអំពីកំណើនសមត្ថភាព ភាពក្លាហាន និងទំនុកចិត្ត ក្នុងការចូលរួមបញ្ចេញមតិយោបល់ នៅក្នុងកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា និងវេទិកាសាធារណៈ ក៏ដូចជាសមត្ថភាពក្នុងការធ្វើការសម្រេចចិត្ត និងការតាំងចិត្តក្នុងការលើកកម្ពស់អភិបាលកិច្ចមូលដ្ឋានដែលមានបរិយាបន្ន ភាពឆ្លើយតប និងគណនេយ្យ ដែលអាចឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានបានកាន់តែប្រសើរ។

ភាពជោគជ័យនេះ បានបញ្ជាក់អំពីតម្លៃ និងលទ្ធផលនៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងការផ្តល់ភាពអង់អាចដល់តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងបញ្ជាក់អំពីសារៈសំខាន់នៃការបន្តវិនិយោគលើការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ការអភិវឌ្ឍសមត្ថភាពនៅក្នុងអភិបាលកិច្ចមូលដ្ឋាន។

## ដំណើរការសំខាន់ៗ

ដើម្បីធានាបាននូវការអនុវត្តប្រកបដោយជោគជ័យ ការពង្រឹងស្ថាប័នបណ្តុះបណ្តាល និងផលជះជាវិជ្ជមានរយៈពេលវែងនៃកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដំណើរការសំខាន់ៗដូចខាងក្រោម ត្រូវបានកំណត់ និងអនុវត្ត៖

**ដំណាក់កាលទី១ - កិច្ចសហការ និងការបង្កើតមាតិកា៖**
កម្មវិធី ISD បានសហការយ៉ាងជិតស្និទ្ធជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីបង្កើតមាតិកា និងម៉ូឌុលសម្រាប់វគ្គសិក្សាចំនួនប្រាំ ដែលត្រូវបានរៀបចំឡើងស្របតាមអាណត្តិ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ កិច្ចសហការនេះធានាបានថា ខ្លឹមសារនៃមេរៀនមានភាពពាក់ព័ន្ធជាក់ស្តែងទៅនឹងអាណត្តិ តម្រូវការ និងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា ព្រមទាំងធានានូវភាពជា



↑ សិក្ខាសាលាពិគ្រោះយោបល់អំពីការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក



↑ ការពិភាក្សាក្រុមក្នុងសិក្ខាសាលាពិគ្រោះយោបល់អំពីការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក

ម្ចាស់របស់ស្ថាប័នបណ្តុះបណ្តាល និងការធ្វើសមាហរណកម្មកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធអេឡិចត្រូនិក ទៅក្នុងកម្មវិធីបណ្តុះបណ្តាលរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ។

**ដំណាក់កាលទី២ - ការអនុវត្តសាកល្បង និងការកែលម្អ៖** កម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក បានដាក់អនុវត្តសាកល្បងនៅក្រុង ស្រុក ចំនួនដប់ ដែលបានជ្រើសរើស ហើយក្រុមប្រឹក្សាអាចស្វ័យសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនេះ នៅមណ្ឌលសិក្សាដែលបានរៀបចំនៅតាមរដ្ឋបាលក្រុង ស្រុក នីមួយៗ។ ដំណាក់កាលសាកល្បងនេះគឺជាការអនុវត្តសាកល្បងជាក់ស្តែងលើមាតិកាខ្លឹមសារមេរៀននៅក្នុងម៉ូឌុលនីមួយៗ និងវេទិកាសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកដើម្បីប្រមូលមតិកែលម្អ និងយោបល់ត្រឡប់ពីអ្នកចូលរួម ដើម្បីកែលម្អលើខ្លឹមសារនៃកម្មវិធីសិក្សាលទ្ធភាពនៃការប្រើប្រាស់ និងវិធីសាស្ត្រក្នុងការសិក្សា។

**ដំណាក់កាលទី ៣ - ការផ្តល់ការប្រឹក្សាយោបល់ (បង្ហាត់បង្ហាញ) និងការគាំទ្រផ្នែកបច្ចេកទេស៖** ក្រុមប្រឹក្សាទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងការប្រឹក្សាយោបល់ (ការបង្ហាត់បង្ហាញ) បន្ថែម ដើម្បីពង្រឹងជំនាញឌីជីថល និងអាចប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកបានពេញលេញ។ កត្តាទាំងនេះបានធ្វើឱ្យមានការចូលរួមយ៉ាងសកម្ម និងការកើនឡើងនូវចំនួនក្រុមប្រឹក្សាដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ។

**ដំណាក់កាលទី ៤ - ការពង្រឹងសមត្ថភាពសម្រាប់ក្រុមការងារសាលាជាតិរដ្ឋបាលមូលដ្ឋានអំពីកម្មវិធី "Atingi"៖** ដើម្បីធានាបាននូវនិរន្តរភាពរយៈពេលវែង មន្ត្រីសំខាន់ៗរបស់សាលាជាតិរដ្ឋបាលមូលដ្ឋាន បានទទួលការបណ្តុះបណ្តាលអំពីការគ្រប់គ្រង និងការធ្វើប្រតិបត្តិការ ប្រព័ន្ធសិក្សាអេឡិចត្រូនិក "Atingi" ដែលបានធ្វើឡើងតាមរយៈការបណ្តុះបណ្តាលដោយផ្ទាល់ពីអ្នកជំនាញការ និងការផ្តល់ឱកាសសហការរៀបចំខ្លឹមសារមេរៀនតាំងពីដំណាក់កាលដំបូងផងដែរ។ ការកសាងសមត្ថភាពនេះ អាចឱ្យក្រុមការងារសាលាជាតិរដ្ឋបាលមូលដ្ឋានមានចំណេះដឹងក្នុងការគ្រប់គ្រងប្រព័ន្ធ ធ្វើបច្ចុប្បន្នភាព និងកែសម្រួលខ្លឹមសារមាតិកាមេរៀន ដើម្បីឱ្យស្របតាមតម្រូវការ និងកម្មវិធីបណ្តុះបណ្តាលរបស់សាលាជាតិនាពេលអនាគត ដែលធានាឱ្យមាននិរន្តរភាពរយៈពេលវែង។

## និរន្តរភាព

ការបង្កើតកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនេះ ជាគំនិតផ្តួចផ្តើមដ៏មានសារៈសំខាន់ និងប្រកបដោយនិរន្តរភាពសំដៅបង្កើន និងពង្រឹងសមត្ថភាពស្ថាប័ន របស់ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងពង្រឹងអភិបាលកិច្ចមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។ តាមរយៈការផ្តល់ចំណេះដឹង និងជំនាញដល់ក្រុមប្រឹក្សា និងតាមរយៈការកសាងសមត្ថភាពរយៈពេលវែងរបស់ស្ថាប័នជាតិ ដូចជាសាលាជាតិរដ្ឋបាលមូលដ្ឋាន ដើម្បីគ្រប់គ្រង និងកែសម្រួលប្រព័ន្ធនេះ វាជាមូលដ្ឋានគ្រឹះសម្រាប់កសាងរដ្ឋបាលមូលដ្ឋាន ដែលមានភាពឆ្លើយតប មានគណនេយ្យភាព និងមានប្រសិទ្ធភាពជាងមុន ដែលអាចបន្តបំពេញតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ បទពិសោធន៍នៃការរៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនេះ នឹងផ្តល់ឱកាសដល់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្នុងការរៀបចំការបណ្តុះបណ្តាលលើខ្លឹមសារ និងក្រុមគោលដៅផ្សេងៗទៀតដែលអាចធ្វើឱ្យសាលាមានកម្មវិធីបណ្តុះបណ្តាលតាមវិធីសាស្ត្រនានា កាន់តែសំបូរបែប ដែលមានភាពបត់បែន និងផ្អែកតាមលទ្ធភាពធនធាន។



↑ វគ្គបណ្តុះបណ្តាលស្តីពីការវិភាគហិរញ្ញវត្ថុសំរាប់សេវាគ្រប់គ្រងសំរាម និងការិយាល័យច្រកចេញចូលតែមួយ

# វិមជ្ឈការហិរញ្ញវត្ថុ

## សមិទ្ធផលសំខាន់ៗ

នីតិវិធីចំនួន ០៨ នៃការវិភាគហិរញ្ញវត្ថុ (ចំណូល ចំណាយ) លើការគ្រប់គ្រងសំរាម សំណល់រឹង និងការិយាល័យច្រកចេញចូលតែមួយ ត្រូវបានបង្កើត និងអនុម័តជាផ្លូវការ ដោយក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុក គោលដៅចំនួនបួន៖ ក្រុងបាត់ដំបង ស្រុកមោងឫស្សី ក្រុងសៀមរាប និងស្រុកសូទ្រនិគម។ តាមរយៈគំនិតផ្តួចផ្តើមនេះ រដ្ឋបាលក្រុង ស្រុក ទទួលបានជំនាញជាក់លាក់ ក្នុងការប៉ាន់ប្រមាណចំណាយការផ្តល់សេវា ព្យាករណ៍ចំណូល និងវិភាគរកគម្លាតហិរញ្ញវត្ថុ ដែលផ្តល់អំណាចដល់ពួកគាត់ ក្នុងការធ្វើការសម្រេចចិត្តលើការប្រើប្រាស់ថវិកា ដោយផ្អែកលើទិន្នន័យ និងភស្តុតាងជាក់ស្តែង។ ជាលទ្ធផល រដ្ឋបាលក្រុង ស្រុកទាំងបួន បានអនុវត្តការវិភាគហិរញ្ញវត្ថុនេះ ដើម្បីពង្រឹងការធ្វើផែនការថវិកា ការបែងចែកធនធាន និងការផ្តល់សេវា។ ការវិភាគហិរញ្ញវត្ថុនេះ បានធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងហិរញ្ញវត្ថុនៅរដ្ឋបាលក្រុង ស្រុក តម្លាភាព និងគណនេយ្យភាព ដោយធានាថាការសម្រេចចិត្តនានា ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងសេវាត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ កាន់តែមានប្រសិទ្ធភាព។ លើសពីនេះ សំណើស្តីអំពីការពិនិត្យឡើងវិញនូវរូបមន្ត និងលក្ខណៈវិនិច្ឆ័យនៃមូលនិធិក្រុង ស្រុក និងការសិក្សាប្រភេទចំណូលមិនមែនសារពើពន្ធថ្មី ដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ត្រូវបានរៀបចំឡើង ដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការពិចារណាលើការផ្ទេរធនធានបន្ថែម ទៅរដ្ឋបាលក្រុង ស្រុក។ ជាលទ្ធផល វានឹងអាចឱ្យរដ្ឋបាលក្រុង ស្រុក មានស្វយភាពកាន់តែច្រើនលើការគ្រប់គ្រងហិរញ្ញវត្ថុ និងបង្កើនចំណូលរបស់ពួកគេ ដើម្បីផ្តល់សេវាសាធារណៈកាន់តែប្រសើរឡើងដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ដំណើរការសំខាន់ៗ

**១. ការរៀបចំនីតិវិធីវិភាគហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹង និង ការិយាល័យច្រកចេញចូលតែមួយ បានអនុវត្តតាមបីដំណាក់កាលដូចខាងក្រោម៖**

**ដំណាក់កាលទី ១ - ការរៀបចំ និងការប្រមូលទិន្នន័យ៖** រដ្ឋបាលក្រុង ស្រុក គោលដៅទាំងបួន បានធ្វើការប្រមូលទិន្នន័យ ដោយប្រើទិន្នន័យផែនទីខ្នងផ្ទះ និងអាជីវកម្ម (ដែលបានធ្វើឡើង និងរក្សាទុកក្នុងកម្មវិធី QGIS)។ បន្ទាប់មក រដ្ឋបាលក្រុង ស្រុក បានកំណត់ចំនួនអ្នកប្រើប្រាស់សេវាប្រមូលសំរាម និងប្រភេទសេវា ដែលបានស្នើសុំនៅការិយាល័យច្រកចេញចូលតែមួយ។

**ដំណាក់កាលទី ២ - ការវិភាគ និងការពិនិត្យឡើងវិញ៖** ដោយផ្អែកលើលទ្ធផលពីដំណាក់កាលទី១ រដ្ឋបាលក្រុង ស្រុក គោលដៅទាំងបួន បានប៉ាន់ប្រមាណចំណាយការផ្តល់សេវា ព្យាករណ៍ចំណូល ដើម្បីវិភាគរកគម្លាតហិរញ្ញវត្ថុសម្រាប់រៀបចំសេចក្តីព្រាងនីតិវិធីលើកទី១។ បន្ទាប់មក រដ្ឋបាលក្រុង ស្រុក បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយការិយាល័យ និងអ្នកពាក់ព័ន្ធ ដើម្បីពិនិត្យមើលសេចក្តីព្រាង ប្រមូលមតិត្រឡប់ និងកែលម្អខ្លឹមសារ ដើម្បីធានាភាពត្រឹមត្រូវ ពេញលេញ និងលទ្ធភាពដែលអាចអនុវត្តបាន។

**ដំណាក់កាលទី ៣ - ការអភិវឌ្ឍសមត្ថភាព ការវាយតម្លៃ និងការអនុម័ត៖** រដ្ឋបាលក្រុង ស្រុកគោលដៅទាំងបួនបានរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពមន្ត្រីរបស់រដ្ឋបាលក្រុង ស្រុក ក្នុងការរៀបចំ និងអនុវត្តនីតិវិធីនៃការវិភាគហិរញ្ញវត្ថុនេះ ប្រកបដោយប្រសិទ្ធភាព។ បន្ទាប់មក រដ្ឋបាលក្រុង ស្រុក បាន

### III. គំរូលទ្ធផល- គម្លាតហិរញ្ញវត្ថុ-ស្រុកសូទ្រនិគម

- រដ្ឋបាលស្រុកសូទ្រនិគមមិនមានគម្លាតថវិកាសម្រាប់អនុវត្តសកម្មភាពនៃផែនការស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទេ ដោយកញ្ចប់ថវិកាដែលវិភាជពីថ្នាក់ជាតិចំនួនច្រើនជាងបន្តិច។
- ទិន្នន័យចំណូល និងចំណាយរបស់ក្រុមហ៊ុនស៊ីន ទ្រី ហាក់មិនមានភាពសុក្រិតដោយសារតែ តួលេខចំណាយ (៣៥៤ ០០០ ០០០ រៀល) មានទំហំច្រើនជាចំណូល (២៦១ ៣២៧ ០០០ ០០០ រៀល)។




| ការវិភាគលើគម្លាតហិរញ្ញវត្ថុ | | | | | |
|---|---|---|---|---|---|
| ការវិភាគលើគម្រូវជំនួយឧបត្ថម្ភ | 2024 | 2025 | 2026 | 2027 | 2028 |
| I ចំណូលសរុប | 372,847,000 | 376,987,000 | 376,987,000 | 376,987,000 | 376,987,000 |
| I.1 ចំណូលពីការប្រមូលសេវា | 261,327,000 | 261,327,000 | 261,327,000 | 261,327,000 | 261,327,000 |
| I.2 ថវិកាវិភាជន៍ថ្នាក់ជាតិ | 110,520,000 | 115,660,000 | 115,660,000 | 115,660,000 | 115,660,000 |
| I.3 ការគាំទ្រពីដៃគូអភិវឌ្ឍន៍ វិស័យឯកជន សប្បុរសជន អង្គការសង្គមស៊ីវិល និងផ្សេងៗទៀត | 1,000,000 | - | - | - | - |
| I.4 ការផាកពិន័យ | - | - | - | - | - |
| II ចំណាយសរុប | 418,200,000 | 449,380,000 | 464,580,000 | 445,380,000 | 454,980,000 |
| II.1 ចំណាយលើការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជាទូទៅរបស់រដ្ឋបាលស្រុក | - | - | - | - | - |
| II.2 ចំណាយលើការប្រមូលសំរាម សំណល់រឹងទីប្រជុំជន និងការរៀបចំទីលានចាក់សំរាម របស់ក្រុមហ៊ុនស៊ីនទ្រី | 354,600,000 | 354,600,000 | 354,600,000 | 354,600,000 | 354,600,000 |
| II.3 ចំណាយអនុវត្តសកម្មភាពតាមផែនការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន | 63,600,000 | 94,780,000 | 109,980,000 | 90,780,000 | 100,380,000 |
| គម្លាតហិរញ្ញវត្ថុ ( ដកចេញចំណូលI.1 និងចំណាយ II.2 ) | 47,920,000 | 20,880,000 | 5,680,000 | 24,880,000 | 15,280,000 |

រូបទី២៖ ក្រាហ្វនៃការវិភាគហិរញ្ញវត្ថុសម្រាប់សេវាគ្រប់គ្រងសំរាម សំណល់រឹង របស់ស្រុក

ធ្វើបទបង្ហាញអំពីសេចក្តីព្រាងនីតិវិធីនេះ ដល់គណៈអភិបាល ក្រុមប្រឹក្សាក្រុង ស្រុក និងមន្ត្រីពាក់ព័ន្ធ ដើម្បីធ្វើការបំភ្លឺបន្ថែម ផ្តល់មតិត្រឡប់ និងកែលម្អ។ ជាចុងក្រោយ ក្រុមប្រឹក្សាក្រុង ស្រុក បានពិភាក្សា និងអនុម័តជាផ្លូវការឱ្យប្រើប្រាស់នីតិវិធីនេះ សម្រាប់ធ្វើការវិភាគហិរញ្ញវត្ថុនៅរដ្ឋបាលក្រុង ស្រុក។

**២. ការរៀបចំសំណើអំពីការពិនិត្យឡើងវិញនូវរូបមន្ត និងលក្ខណៈវិនិច្ឆ័យនៃមូលនិធិក្រុង ស្រុក និងការសិក្សាប្រភេទថ្មីនៃចំណូលមិនមែនសារពើពន្ធសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក បានអនុវត្តតាមបួនដំណាក់កាលដូចខាងក្រោម៖**

**ដំណាក់កាលទី១៖** សិក្សា និងពិនិត្យមើលបទពិសោធន៍អន្តរជាតិ និងមូលដ្ឋាន ដើម្បីដកស្រង់ជាមេរៀនសម្រាប់ការវិភាជន៍មូលនិធិ និងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅប្រទេសកម្ពុជា។

**ដំណាក់កាលទី២៖** រៀបចំការស្ទង់មតិជាមួយរដ្ឋបាលក្រុង ស្រុកចំនួន៣៦ នៃខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ។ បន្ទាប់មក រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាមួយរដ្ឋបាលក្រុង ស្រុក ដែលត្រូវបានជ្រើសរើសដែលដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើសុពលភាពលទ្ធផលនៃការស្ទង់មតិ។

**ដំណាក់កាលទី៣៖** រៀបចំសេចក្តីព្រាងសំណើទី១ និងពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីប្រមូលយោបល់ត្រឡប់ និងអនុសាសន៍កែលម្អ។

**ដំណាក់កាលទី៤៖** បញ្ចប់សំណើអំពីការពិនិត្យឡើងវិញនូវរូបមន្ត និងលក្ខណៈវិនិច្ឆ័យនៃមូលនិធិក្រុង ស្រុក និងសិក្សាប្រភេទចំណូលមិនមែនសារពើពន្ធថ្មី សម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ដើម្បីដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិចារណា។ សំណើនេះ គឺជាការត្រួសត្រាយផ្លូវ សម្រាប់ពង្រឹងវិមជ្ឈការហិរញ្ញវត្ថុឱ្យកាន់តែរឹងមាំ និងបង្កើនស្វ័យភាពហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក។

## និរន្តរភាព

និរន្តរភាព ត្រូវបានធានាតាមរយៈការអនុម័តជាផ្លូវការនៃនីតិវិធីវិភាគហិរញ្ញវត្ថុ ដោយក្រុមប្រឹក្សាក្រុង ស្រុក ដោយបញ្ចូលនីតិវិធីវិភាគហិរញ្ញវត្ថុ ទៅក្នុងប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាន។ ការចែករំលែកចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងបានពង្រឹងសមត្ថភាពរបស់មន្ត្រី ក្នុងការប៉ាន់ប្រមាណចំណូល-ចំណាយ និងការធ្វើការសម្រេចចិត្តដោយផ្អែកលើទិន្នន័យ។ ឥឡូវនេះ រដ្ឋបាលក្រុង ស្រុក អាចយកជំនាញ និងវិធីសាស្ត្រទាំងនេះ មកប្រើប្រាស់ ដើម្បីពង្រីកទៅកាន់សេវាផ្សេងទៀត ក្នុងការវិភាគហិរញ្ញវត្ថុ (ឧ. សេវាសង្គម។ល។)។ ការណ៍នេះ បានលើកកម្ពស់ ឱ្យមានធ្វើផែនការហិរញ្ញវត្ថុបានត្រឹមត្រូវ ការផ្តល់សេវាកាន់តែប្រសើរឡើង និងការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ កាន់តែល្អក្នុងរយៈពេលវែង។ ទន្ទឹមនឹងនេះ សំណើដែលបានដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបម្រើជាធាតុចូល សម្រាប់ការអភិវឌ្ឍក្របខ័ណ្ឌច្បាប់ ដែលមាននិរន្តរភាព សម្រាប់ការផ្ទេរធនធានបន្ថែមដល់រដ្ឋបាលក្រុង ស្រុក ប្រកបដោយសមភាព និងសមធម៌។ កត្តានេះធានាបាននូវការបន្តផ្តល់សិទ្ធិអំណាចផ្នែកហិរញ្ញវត្ថុដល់រដ្ឋបាលក្រុង ស្រុក និងការផ្តល់សេវាប្រសើរជាងមុន។



↑ ការផ្តល់សេវាចល័តរបស់ការិយាល័យច្រកចេញចូលតែមួយ

# ការកែលម្អការផ្តល់សេវារដ្ឋបាលផ្តោតលើប្រជាពលរដ្ឋ

រដ្ឋបាលក្រុង ស្រុក ដែលបានជ្រើសរើសក្នុងខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប បានទទួលការគាំទ្រ ដើម្បីលើកកម្ពស់ការផ្តល់សេវារដ្ឋបាល តាមរយៈការពង្រឹងគុណភាពការផ្តល់សេវាដោយផ្ទាល់ និងការផ្តល់សេវាតាមប្រព័ន្ធអនឡាញរបស់ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក។

## សមិទ្ធផលសំខាន់ៗ

ការគាំទ្ររបស់កម្មវិធី ISD ផ្នែកការិយាល័យច្រកចេញចូលតែមួយ បានបង្កើនប្រសិទ្ធភាព និងតម្លាភាព ព្រមទាំងពង្រីកវិសាលភាព នៃការផ្តល់សេវារដ្ឋបាលសំខាន់ៗជូនប្រជាពលរដ្ឋ តាមរយៈការសាកល្បងគំរូ នៃការផ្តល់សេវាតាមប្រព័ន្ធអនឡាញ និងការផ្តល់សេវារដ្ឋបាលចល័ត ដោយផ្តល់ការយកចិត្តទុកដាក់ជាពិសេសចំពោះប្រជាពលរដ្ឋ ដែលជួបការលំបាករស់នៅតំបន់ដាច់ស្រយាល។

ដោយមានការគាំទ្រពីក្រសួងមហាផ្ទៃ ការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ របស់ការិយាល័យច្រកចេញចូលតែមួយ បានចាប់ផ្តើមដំណើរការនាខែសីហា ឆ្នាំ២០២៤ ក្នុងទម្រង់ជាថ្នាលផ្តល់សេវារដ្ឋបាល តាមគេហទំព័របែបកូនកាត់ ដើម្បីឱ្យប្រជាពលរដ្ឋ អាចស្នើសុំសេវាចាំបាច់មួយចំនួន និងអាចធ្វើការទូទាត់សាច់ប្រាក់តាមប្រព័ន្ធអនឡាញ។ ប្រជាពលរដ្ឋ ក៏អាចស្វែងរកព័ត៌មាននៃការផ្តល់សេវា និងព័ត៌មាននៃការស្នើសុំសេវា តាមរយៈកម្មវិធីទូរសព្ទដៃ OWSM CAMBODIA App[1] បានដែរ។

ការអនុវត្តសាកល្បង ការផ្តល់សេវាចល័តរបស់ការិយាល័យច្រកចេញចូលតែមួយនេះ ត្រូវបានដាក់បញ្ចូលរួមគ្នាជាមួយនឹងយន្តការនៃការទទួលមតិយោបល់ត្រឡប់ និងបណ្តឹងនានាជាមួយការិយាល័យប្រជាពលរដ្ឋ ដែលធ្វើឱ្យកាន់តែងាយស្រួលសម្រាប់ប្រជាពលរដ្ឋ ក្នុងការចែករំលែកមតិកែលម្អ និងបង្កើនការយល់ដឹងអំពីសេវានានា និងសិទ្ធិរបស់ប្រជាពលរដ្ឋ។ ក្នុងរយៈពេលមួយឆ្នាំ ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលស្រុកទាំងពីរ ដែលបានជ្រើសរើសសម្រាប់ការអនុវត្តសាកល្បង បានផ្តល់សេវារដ្ឋបាលដល់ប្រជាពលរដ្ឋ ដែលជួបការលំបាករស់នៅក្នុងភូមិដាច់ស្រយាលចំនួន ១៤ភូមិ ដោយផ្តល់សេវាជាង ៥.០០០សេវា ដល់ប្រជាពលរដ្ឋប្រមាណ ១០.០០០នាក់ ដែលក្នុងចំណោមនេះមាន ២៥% ជាប្រជាពលរដ្ឋដែលជួបការលំបាក។

## ដំណើរការសំខាន់ៗ

ដំណើរការអនុវត្តសាកល្បងនេះ បានចាប់ផ្តើមឡើង ដោយការវាយតម្លៃលើប្រព័ន្ធ នៃការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលក្រុង ស្រុក ដើម្បីកំណត់ពីតម្រូវការ និងសេវាអាទិភាពដែលត្រូវផ្តល់តាមប្រព័ន្ធអនឡាញ។ លទ្ធផលនៃការធ្វើការវាយតម្លៃអំពីការត្រៀមខ្លួន ក្នុងការផ្តល់សេវាតាមប្រព័ន្ធអនឡាញរបស់ការិយាល័យច្រកចេញចូលតែមួយ បានផ្តល់ជាមូលដ្ឋានក្នុងការកំណត់ពី វគ្គបណ្តុះបណ្តាល ប្រព័ន្ធការងារ និងឧបករណ៍ចាំបាច់នានា ដើម្បីបង្កើនប្រសិទ្ធភាព នៃការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ ទាំងការផ្តល់សេវានៅការិយាល័យផ្ទាល់ ការផ្តល់សេវាតាមប្រព័ន្ធអនឡាញ និងការផ្តល់សេវាចល័ត។



↑ ក្រុមការងារការិយាល័យច្រកចេញចូលតែមួយផ្តល់សេវាជូនប្រជាពលរដ្ឋនៅសហគមន៍

1 យ៉ាងណាក៏ដោយ រហូតមកដល់ពេលនេះ ម្ចាស់អាជីវកម្ម និងប្រជាពលរដ្ឋនៅតែត្រូវបង្ហាញឯកសារសេវាដែលពាក់ព័ន្ធនៅការិយាល័យច្រកចេញចូលតែមួយនៃក្រុង ស្រុក ខណ្ឌ។





↑ វគ្គបណ្តុះបណ្តាលអំពីការផ្តល់សេវាតាមប្រព័ន្ធអនឡាញរបស់ការិយាល័យច្រកចេញចូលតែមួយ

← ក្រុមការងារផ្តល់សេវាចល័តផ្តល់សេវាជូនប្រជាពលរដ្ឋនៅភូមិបណ្តែតទឹកក្នុងស្រុកពួក

កម្មវិធី ISD បានផ្តល់វគ្គបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ដែលបានជ្រើសរើសសម្រាប់ការអនុវត្តសាកល្បងលើប្រធានបទដូចជា៖ ការផ្តល់សេវាដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ការប្រើប្រាស់កម្មវិធីព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រង និងផ្តល់សេវារដ្ឋបាល ការផ្តល់សេវាតាមប្រព័ន្ធអនឡាញ (កម្មវិធីទូរសព្ទដៃ OWSM CAMBODIA) របស់ការិយាល័យច្រកចេញចូលតែមួយ។ ក្រៅពីនេះ កម្មវិធី ក៏បានផ្តល់សម្ភារៈចាំបាច់មួយចំនួនសម្រាប់អនុវត្តការងារផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ ការផ្តល់សេវាចល័ត និងការផ្តល់សេវាតាមប្រព័ន្ធអនឡាញ (ឧ. ប្រព័ន្ធផ្ទុកទិន្នន័យព័ត៌មានវិទ្យា កុំព្យូទ័រយួរដៃ ម៉ូតូ និងម៉ូតូកង់បី ជាដើម)។

ក្នុងពេលដំណាលគ្នានោះ គំរូនៃការអនុវត្តសាកល្បងការផ្តល់សេវារដ្ឋបាលតាមប្រព័ន្ធអនឡាញ និងសេវាចល័ត្រូវបានបង្កើតឡើង ធ្វើតេស្តនៅក្នុងមូលដ្ឋាន និងកែលម្អដោយផ្អែកលើមតិយោបល់របស់អ្នកប្រើប្រាស់។ ដោយមានការគាំទ្រពីនាយកដ្ឋានមុខងារ និងធនធាន នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ថ្នាលផ្តល់សេវាតាមប្រព័ន្ធអនឡាញ ត្រូវបានដាក់ឱ្យដំណើរការនាខែសីហា ឆ្នាំ ២០២៤។ ការផ្តល់សេវាចល័ត បានរួមបញ្ចូលគ្នានូវសេវាការិយាល័យច្រកចេញចូលតែមួយ និងសេវារបស់ការិយាល័យប្រជាពលរដ្ឋ ដោយបានប្រើប្រាស់ម៉ូតូ និងម៉ូតូកង់បី ហើយនៅរដូវវស្សា ដោយប្រើប្រាស់ទូក ដើម្បីផ្តល់សេវាទៅដល់សហគមន៍។

ជាចុងក្រោយ ស្រុកសាកល្បងទាំងពីរ បានទទួលការគាំទ្រ ក្នុងការរៀបចំផែនការ និងសម្ភារៈផ្សព្វផ្សាយព័ត៌មានអំពីការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ សេវាអនឡាញ និងសេវាចល័ត ដើម្បីគាំទ្រការអនុវត្តផែនការទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មានសម្រាប់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## និរន្តរភាព

គំនិតផ្តួចផ្តើម របស់ការិយាល័យច្រកចេញចូលតែមួយ បានពង្រឹង**និរន្តរភាពសង្គម និងវប្បធម៌** ដោយធានាថា ការផ្តល់សេវាត្រូវផ្តោតលើប្រជាពលរដ្ឋ ប្រកបដោយបរិយាបន្ន តម្លាភាព និងការឆ្លើយតប។ សេវាតាមប្រព័ន្ធអនឡាញ ដែលបានដាក់ឱ្យដំណើរការ បានឆ្លើយតបនឹងសេចក្តីត្រូវការ ៩០% ក្នុងមូលដ្ឋាន និងផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់សម្រាប់ប្រជាពលរដ្ឋ (វ័យក្មេង)។ ថ្នាលផ្តល់សេវាតាមប្រព័ន្ធអនឡាញ និងសេវាចល័តរបស់ការិយាល័យច្រកចេញចូលតែមួយ ត្រូវបានរចនារួមគ្នាដោយមានការចូលរួមពីប្រជាពលរដ្ឋ និងរដ្ឋបាលក្រុង ស្រុក ដើម្បីលើកកម្ពស់ភាពជាម្ចាស់ និងការប្រើប្រាស់រយៈពេលវែង។ ដើម្បីធានាថា គ្រប់គ្នាទទួលបានព័ត៌មាន សម្ភារៈផ្សព្វផ្សាយព័ត៌មានជារូបភាព ត្រូវបានរៀបចំជាជំនួយ ដល់ប្រជាពលរដ្ឋដែលអក្ខរកម្ម ហើយមន្ត្រីរបស់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ បានផ្តល់ការគាំទ្រដល់អ្នកដែលមានតម្រូវការពិសេស។

**និរន្តរភាពផ្នែកបច្ចេកទេស៖** ការិយាល័យច្រកចេញចូលតែមួយត្រូវបានបំពាក់ឧបករណ៍ចាំបាច់នានាសម្រាប់ផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងជឿទុកចិត្តបាន។ ប្រព័ន្ធផ្ទុកទិន្នន័យមេគាំទ្រក្រសួងមហាផ្ទៃក្នុងការផ្តល់សេវានៅទូទាំងប្រទេស។ មតិយោបល់ ដែលអ្នកប្រើប្រាស់ផ្តល់ជាបន្តបន្ទាប់ ជួយកែលម្អថ្នាលផ្តល់សេវាតាមប្រព័ន្ធអនឡាញ និងការផ្តល់សេវាចល័តឱ្យមានភាពងាយស្រួលប្រើប្រាស់។

**និរន្តរភាពផ្នែកហិរញ្ញវត្ថុ៖** ស្រុកដែលអនុវត្តសាកល្បង បានបញ្ចូលនូវផែនការថវិកាសម្រាប់ប្រតិបត្តិការ និងសកម្មភាពលើកកម្ពស់ការយល់ដឹង អំពីការិយាល័យច្រកចេញចូលតែមួយទៅក្នុងកម្មវិធីវិនិយោគរបស់រដ្ឋបាលស្រុក។



↑ ប្រព័ន្ធធុងសំរាមបីប្រភេទ ដែលអនុវត្តនៅសាលា

# ការដោះស្រាយបញ្ហាគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយនិរន្តភាព៖ ការផ្តល់សិទ្ធអំណាចដល់សហគមន៍ និងរដ្ឋបាលមូលដ្ឋាន

កម្មវិធី ISD បានគាំទ្រក្រុង ស្រុកចំនួនប្រាំមួយ ដែលស្ថិតនៅខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប ដើម្បីរៀបចំ និងអនុវត្តផែនការគ្រប់គ្រងសំរាម សំណល់រឹងនៅទីប្រជុំជន និងដាក់បញ្ចូលសកម្មភាពអាទិភាពទៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលក្រុង ស្រុក ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើង ដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅប្រទេសកម្ពុជា។

## សមិទ្ធផលសំខាន់ៗ

**លទ្ធភាពក្នុងការទទួល និងការផ្តល់សេវាប្រមូលសំរាម មានភាពប្រសើរឡើង** តាមរយៈការរៀបចំប្រព័ន្ធគ្រប់គ្រងសំរាមតាមសហគមន៍នៅតំបន់ជនបទ និងទីប្រជុំជន។ រដ្ឋបាលក្រុងសៀមរាប បានរៀបចំទីតាំងទុកដាក់សំរាមបណ្តោះអាសន្ន (ដោយមានការបែងចែកប្រភេទសំរាម) និងម៉ូតូកង់បីដឹកសំរាម នៅក្នុងសង្កាត់សំបួរ ដើម្បីធានាបាននូវការប្រមូលសំរាមជាប្រចាំ។ ការរៀបចំនេះ បានកាត់បន្ថយការបោះសំរាមនៅទីសាធារណៈនៅសហគមន៍ និងបានរួមចំណែកដល់ការធ្វើឱ្យប្រសើរឡើង នូវសុខភាពសាធារណៈ ដែលមានអ្នកទទួលផលចំនួនប្រមាណ ៦០០ គ្រួសារ (ប្រជាពលរដ្ឋ ២.៦០០នាក់ ដែលមានស្រីចំនួន ១.៣៨១ នាក់)។ ការរៀបចំឱ្យមានប្រព័ន្ធប្រមូលសំរាមនៅក្នុងសហគមន៍បណ្តែតទឹក ក្នុងឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម បានធ្វើឱ្យមានការប្រមូលសំរាមទៀងទាត់សម្រាប់ប្រជាពលរដ្ឋចំនួន ២.៧១៨ គ្រួសារ (≈៨.០៦១ នាក់ ដែលមានស្រី ៤.១៥១ នាក់)។ ក្រុងប៉ោយប៉ែត ក្រុងបាត់ដំបង និងក្រុងសៀមរាប បានអនុវត្តប្រព័ន្ធគ្រប់គ្រងការញែកសំរាមជាបីប្រភេទ (ដូចជា សំណល់សរីរាង្គ សំណល់ប្លាស្ទិក និងសំណល់ដែលមិនអាចកែច្នៃបាន) ជាវិធីសាស្ត្រដែលជំរុញឱ្យមានការញែកសំរាមនៅប្រភព ផ្តល់ផលប្រយោជន៍ដល់ប្រជាជនរាប់ពាន់នាក់ និងចូលរួមចំណែកបង្កើតបរិយាកាសស្អាត និងមានផាសុកភាពជាងមុន។

**ការស្តារធនធានឡើងវិញតាមរយៈការកែច្នៃ និងការអនុវត្តសេដ្ឋកិច្ចចក្រា ត្រូវបានពង្រឹង** តាមរយៈការផ្តួចផ្តើមគំនិតនៅមូលដ្ឋាន។ បច្ចុប្បន្ន ការសង់ស្ថានីយផលិតជីកំប៉ុស្ដិ៍ នៅស្រុកសូទ្រនិគម បានបំលែងសំណល់សរីរាង្គ ទៅជាជីកំប៉ុស្ដិ៍ ដែលអនុញ្ញាតឱ្យប្រជាកសិករប្រើប្រាស់ជីធម្មជាតិសម្រាប់ដំណាំកសិកម្ម ប្រកបដោយនិរន្តរភាព មានតម្លៃសមរម្យ និងកាត់បន្ថយការប្រើប្រាស់ជីគីមី។ ស្ថានីយនេះ ផ្តល់ជាប្រយោជន៍ដោយផ្ទាល់ដល់ប្រជាកសិករប្រមាណ ៣.០០០ នាក់ (ស្រី ១.៦៥៤ នាក់)។ ការផ្តួចផ្តើមគំនិត ក្នុងការកែច្នៃចំណីអាហារក្នុងស្រុកបានប្រែក្លាយផ្លែឈើ និងបន្លែដែលត្រូវបោះចោលទៅជាផលិតផលអាហារ។ គំនិតផ្តួចផ្តើមនេះ បានបង្កើតឱកាសការងារ និងកាត់បន្ថយសំណល់អាហារទៅទីលានចាក់សំរាម។ ការចាប់ផ្តើមអនុវត្តប្រព័ន្ធញែកសំរាមជាបីប្រភេទ និងការបំពាក់ម៉ាស៊ីនចម្រោះទឹកនៅតាមសាលារៀន និងរដ្ឋបាលក្រុង ស្រុក បានជួយកាត់បន្ថយការប្រើប្រាស់សំណល់ប្លាស្ទិក និងផ្សព្វផ្សាយទំលាប់អនុវត្តប្រកបដោយនិរន្តភាព ក្នុងចំណោមសិស្សានុសិស្ស និងមន្ត្រីថ្នាក់មូលដ្ឋាន។

**ការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹង ត្រូវបានបញ្ចូលជាផ្នែកមួយនៃប្រព័ន្ធស្ថាប័ន** តាមរយៈក្របខ័ណ្ឌច្បាប់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការពង្រឹងការអនុវត្តអនុក្រឹត្យលេខ១១៣ បានជំរុញឱ្យមានការគ្រប់គ្រងសំរាមតាមបែបវិមជ្ឈការ ចំណែកក្រុង ស្រុក ចំនួនប្រាំមួយ បានអនុម័ត និងអនុវត្តផែនការគ្រប់គ្រងសំរាម សំណល់រឹងជាផ្លូវការ ជាមួយថវិកាដែលបានបែងចែក។ ការអនុវត្តដីកាស្តីពីតម្លៃសេវាប្រមូលសំរាម និងការផាកពិន័យនៅទូទាំងក្រុង ស្រុក ទាំង៦ គឺជាមូលដ្ឋានគ្រឹះក្នុងការធានាឱ្យមាននិរន្តរភាពហិរញ្ញវត្ថុ។ លើសពីនេះ ស្រុកចំនួនបី បានធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាម សំណល់រឹង ទៅឱ្យ ឃុំ និងសង្កាត់ ក្នុងគោលបំណងបង្កើនភាពជាម្ចាស់ កិច្ចសហការ ប្រសិទ្ធភាពប្រតិបត្តិការ និង

គណនេយ្យភាព។ សៀវភៅណែនាំអំពីការគ្រប់គ្រងសំរាម សំណល់រឹង ដែលបានចងក្រងពីការអនុវត្តសាកល្បងរបស់ក្រុង ស្រុកទាំង៦ បច្ចុប្បន្នបានក្លាយជាការណែនាំក្នុងការពង្រីកវិសាលភាព នៃការអនុវត្តគ្រប់គ្រងសំរាមនៅទូទាំងប្រទេស។

**សមត្ថភាពរដ្ឋបាលក្រុង ស្រុក និងការអនុវត្តការងារគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយនិរន្តរភាពត្រូវបានពង្រឹង៖** សមត្ថភាព និងការយល់ដឹងអំពីការគ្រប់គ្រងសំរាម សំណល់រឹងរបស់មន្ត្រីថ្នាក់មូលដ្ឋាន និងសហគមន៍មានភាពប្រសើរឡើង។

បរិមាណសំណល់ប្លាស្ទិក មានការធ្លាក់ចុះ តាមរយៈការអនុវត្តវិធានការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិកមួយចំនួន ដែលរួមមានការបំពាក់ប្រព័ន្ធចម្រោះទឹកនៅតាមរដ្ឋបាលក្រុង ស្រុក និងសាលារៀន។ គ្រូបង្គោល ដែលបានទទួលការបណ្តុះបណ្តាលនៅមូលដ្ឋាន

## ដំណើរការសំខាន់ៗ

### លំហូរដំណើរការគ្រប់គ្រងសំរាម សំណល់រឹង (ការបង្កើត -> ការអនុវត្ត -> ដំណោះស្រាយជាក់ស្តែង)






↑ ឡានតូចសម្រាប់ប្រមូលសំរាម(លើ)។ ស្ថានីយ៍ប្រមូលសំរាម សំបួរ (ស្តាំ) →



បន្តលើកកម្ពស់ការយល់ដឹង និងការផ្លាស់ប្តូរឥរិយាបថអំពីការគ្រប់គ្រងសំរាម សំណល់រឹងនៅតាមឃុំ សង្កាត់។

## និរន្តរភាព

ការគ្រប់គ្រងសំរាម សំណល់រឹងបានក្លាយវិស័យសំខាន់មួយនៅក្នុងរដ្ឋបាលក្រុង ស្រុក ដោយមានអនុគណៈកម្មាធិការគ្រប់គ្រងសំរាម ដែលបានបង្កើតឡើងជាផ្លូវការដោយក្រុមប្រឹក្សា និងការផ្ទេរតួនាទី និងការទទួលខុសត្រូវពីថ្នាក់ជាតិមកថ្នាក់ក្រោមជាតិ។ សកម្មភាពអាទិភាព ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់ក្រុង ស្រុក ដែលជាការធានាបាននូវនិរន្តរភាពនៃការអនុវត្ត បន្ទាប់ពីការបញ្ចប់គម្រោង។

និរន្តរភាពហិរញ្ញវត្ថុ ត្រូវបានពង្រឹងឡើងវិញតាមរយៈ ការប្រើកញ្ចប់ថវិកាសេវាសង្គម និងអនាម័យបរិស្ថានក្រុង ស្រុក ការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការអនុវត្តប្រព័ន្ធកម្រៃសេវា ការកៀរគរធនធាន និងយន្តការហិរញ្ញប្បទានដោយខ្លួនឯង ដែលកំពុងលេចចេញជារូបរាង ក៏ដូចជាយន្តការនៃការរៀបចំថវិកា និងការស្តារការចំណាយប្រកបដោយប្រសិទ្ធភាព (ការវិភាគការចំណាយលើការផ្តល់សេវា)។

ចំណេះដឹង និងជំនាញ ត្រូវបានពង្រឹង និងពង្រីកនៅក្នុងដំណើរការគ្រប់គ្រងសំរាមទាំងមូល។ បច្ចុប្បន្ន មន្ត្រីរដ្ឋបាលក្រុង ស្រុក មានសមត្ថភាពធ្វើផែនការ និងអនុវត្តផែនការគ្រប់គ្រងសំរាម សំណល់រឹងដោយមានការគាំទ្រពីផ្នែកខាងក្រៅតិចតួចបំផុត បន្ទាប់ពីទទួលបានការគាំទ្រពីកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ដែលធានានិរន្តរភាពនៃការយល់ដឹងនិងការចូលរួមនៅមូលដ្ឋាន។




### ផលប៉ះពាល់

- ភាពប្រសើរឡើងនៃសេវាប្រមូលសំរាម និងការគ្រប់គ្រងសំរាម សំណល់រឹង បានចូលរួមកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក និងលើកកម្ពស់ការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយនិរន្តរភាព និងផ្តល់ផលប្រយោជន៍ដល់គ្រួសាររាប់ពាន់គ្រួសារ នៅ ៦ ក្រុង ស្រុក (១.៤៤៣.៨៧៩នាក់ ស្រី ៤៨៥.៥៥៨នាក់)។
- សហគមន៍ដែលស្អាត និងមានសុខភាពល្អ ជាលទ្ធផលនៃការប្រើជីសរីរាង្គ និងបរិស្ថានល្អប្រសើរទាំងនៅក្នុងតំបន់ទីក្រុង និងតំបន់ដាច់ស្រយាល។
- ប្រព័ន្ធគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយនិរន្តរភាព ដែលត្រូវបានបង្កើតឡើយតាមរយៈការផ្តល់ភាពជាម្ចាស់របស់មូលដ្ឋាន ការបែងចែកថវិកា និងធនធានពីការប្រមូលកម្រៃសេវា ធានាឱ្យមានផលប៉ះពាល់រយៈពេលវែង។



↑ ប្រកទ្វារទឹកនៃអាងស្តុកទឹកទានកាំ

# យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងទឹក

កម្មវិធី ISD ផ្នែកទឹក បានគាំទ្រស្រុក ក្រុង ចំនួនបួនក្នុងខេត្តបន្ទាយមានជ័យ ក្នុងការរៀបចំ និងអនុវត្តផែនការគ្រប់គ្រងទឹក ដែលគិតពីបម្រែបម្រួលអាកាសធាតុរយៈពេលប្រាំឆ្នាំ (CS-WMP) របស់ក្រុង ស្រុក។

## សមិទ្ធផលសំខាន់ៗ

ក្រុង ស្រុក ចំនួនបួននៃខេត្តបន្ទាយមានជ័យ បានបង្កើតអនុគណៈកម្មាធិការគ្រប់គ្រងទឹក និងបរិស្ថាន ដើម្បីគាំទ្រការអនុវត្តអនុក្រឹត្យលេខ ១៨២ និង១៨៤។ អនុគណៈកម្មាធិការគ្រប់គ្រងទឹក និងបរិស្ថាន ជាអ្នកដឹកនាំរៀបចំ និងចងក្រងផែនការគ្រប់គ្រងទឹក ដោយគិតពីបម្រែបម្រួលអាកាសធាតុ ឆ្នាំ ២០២៥-២០៣០ ដោយផ្តោតសំខាន់លើការងារកែលម្អ ប្រតិបត្តិការ និងថែទាំប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពធន់ទៅនឹងអាកាសធាតុ។

ផែនការសកម្មភាព ឆ្នាំ២០២៥ ដែលរួមមាន ការងារជួសជុលប្រព័ន្ធធារាសាស្ត្រ និងសកម្មភាពផ្សេងៗទៀត ត្រូវបានហិរញ្ញប្បទាន តាមរយៈថវិកាក្នុងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលរបស់ ក្រុង ស្រុក និងឃុំ សង្កាត់ និងការចូលរួមថវិកាពីមន្ទីរធនធានទឹក និងឧតុនិយម ព្រមទាំងពីកម្មវិធីនើធ័រ (Nurture)។ ការចូលរួមថវិកាវិនិយោគ សម្រាប់ក្រុង ស្រុកគោលដៅទាំង ៤ សម្រាប់ឆ្នាំ២០២៥ មានចំនួនសរុប ២០០.០០០ ដុល្លារអាមេរិក។ ការអនុវត្តផែនការសកម្មភាពនៃការគ្រប់គ្រងទឹក ដោយគិតពីបម្រែបម្រួលអាកាសធាតុ ឆ្នាំ២០២៥ បានធ្វើឱ្យប្រសើរឡើងនូវកិច្ចប្រតិបត្តិការ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ ព្រមទាំងកាត់បន្ថយជម្លោះទឹក។ ការងារនេះបានរួមចំណែកបង្កើនជីវភាពប្រជាកសិករចំនួន ៤៥.០០០នាក់ រួមទាំងជនងាយរងគ្រោះប្រមាណ ១៣.០០០នាក់ នៅក្នុងឃុំ សង្កាត់ចំនួន ៧។ ឃុំ សង្កាត់ នឹងមានសមត្ថភាពធន់ទ្រាំនឹងការផ្លាស់ប្តូរអាកាសធាតុ និងបញ្ហាសង្គមកាន់តែប្រសើរឡើង ដោយធ្វើការជីកស្រះតូចៗសម្រាប់ស្តុកទឹក ប្រើពូជស្រូវថ្មីៗ និងលើកកម្ពស់ជម្រើសសកម្មភាពគ្រប់គ្រងទឹក និងបច្ចេកទេសដាំដុះ។

## ដំណើរការសំខាន់ៗ

ជាការចាប់ផ្តើម ការវាយតម្លៃសមត្ថភាព និងតម្រូវការចាំបាច់ត្រូវបានធ្វើឡើង ដើម្បីកែលម្អការគ្រប់គ្រង ប្រតិបត្តិការ និងការថែទាំប្រព័ន្ធធារាសាស្ត្រខ្នាតតូច។ បន្ទាប់មក ការបណ្តុះបណ្តាល ត្រូវបានផ្តល់ជូនមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្តោតលើស្រុកដៃគូទាំងបួន។

អនុគណៈកម្មាធិការគ្រប់គ្រងទឹក និងបរិស្ថានក្រុង ស្រុក បានដឹកនាំរៀបចំផែនការគ្រប់គ្រងទឹក ដោយគិតពីបម្រែបម្រួលអាកាសធាតុ ឆ្នាំ២០២៥-២០៣០ ដោយផ្អែកលើការជ្រើសរើសប្រព័ន្ធធារាសាស្ត្រ ដែលមានមុខងារខ្សោយ។ ការងារបន្តគឺផ្តោតលើការរចនាប្លង់បច្ចេកទេស និងការប៉ាន់ស្មានតម្លៃ ដើម្បីកែលម្អការងារកិច្ចប្រតិបត្តិការ និងការថែទាំ។

វឌ្ឍនភាព និងគុណភាពការងារនៃផែនការសកម្មភាពឆ្នាំ២០២៥ ត្រូវបានតាមដាន និងពិនិត្យឡើងវិញ តាមរយៈការចូលរួមវាយតម្លៃរហ័ស។ ការវាយតម្លៃរហ័សនេះ ក៏ត្រូវបានប្រើប្រាស់សម្រាប់អនុវត្តការងារនៃផែនការសកម្មភាពគ្រប់គ្រងទឹកដោយគិតពីបម្រែបម្រួលអាកាសធាតុ សម្រាប់ឆ្នាំបន្តបន្ទាប់។

កម្មវិធី ISD បានជួយគាំទ្រការចងក្រងទិន្នន័យ និងផែនទីប្រព័ន្ធធារាសាស្ត្រ ដោយប្រើប្រាស់កម្មវិធីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ដែលជាប្រភពបើកចំហ។ ក្រុង ស្រុកបានប្រើប្រាស់ផែនទី

ទាំងនេះ សម្រាប់តាមដានវឌ្ឍនភាពការងារ រៀបចំផែនការ និងថវិកាសម្រាប់ផែនការសកម្មភាពឆ្នាំបន្ទាប់ និងដើម្បីគាំទ្រដល់សហគមន៍កសិករប្រើប្រាស់ទឹក ក្នុងកិច្ចប្រតិបត្តិការ និងការថែទាំប្រព័ន្ធធារាសាស្ត្រ។

## និរន្តរភាព

គម្រោងដែលលើកកម្ពស់និរន្តរភាពផ្នែកសង្គម និងវប្បធម៌ បានជំរុញឱ្យមានការគ្រប់គ្រងទឹកដែលប្រកបដោយបរិយាបន្ន តាមរយៈការចូលរួមពីសហគមន៍កសិករប្រើប្រាស់ទឹក និងវិស័យឯកជន ក្នុងដំណើរការជ្រើសរើស និងរៀបចំផែនការសកម្មភាពគ្រប់គ្រងទឹកដោយគិតពីបម្រែបម្រួលអាកាសធាតុ។

ការរួមបញ្ចូលទិន្នន័យកសិកម្ម បរិស្ថាន និងទឹក តាមរយៈប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) គឺជាចំណុចសំខាន់ក្នុងការគាំទ្រការងារអន្តរវិស័យ ក្នុងបរិបទគ្រប់គ្រងទឹកដោយគិតពីបម្រែបម្រួលអាកាសធាតុ ដែលជាការលើកកម្ពស់ និរន្តរភាពផ្នែកបច្ចេកទេស។ ការអនុវត្តការងារប្រព័ន្ធធារាសាស្ត្រត្រូវត្រួតពិនិត្យបច្ចេកទេស និងការអនុលោមតាមវិធានការការពារបរិស្ថាន និងសុវត្ថិភាពសង្គម មុនពេលអនុវត្តគម្រោង។

ថវិកាសរុប សម្រាប់ផែនការសកម្មភាពនៃការគ្រប់គ្រងទឹកដោយគិតពីបម្រែបម្រួលអាកាសធាតុ បានមកពីកម្មវិធីវិនិយោគរបស់ក្រុង ស្រុក និងឃុំ សង្កាត់ ដែលមានការគាំទ្រផ្នែកបច្ចេកទេស និងការត្រួតពិនិត្យពីមន្ទីរធនធានទឹក និងឧតុនិយម ព្រមទាំងដៃគូអភិវឌ្ឍន៍។ វាជាមូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់ធានានិរន្តរភាពហិរញ្ញវត្ថុ និងការលើកកម្ពស់ជីវភាពកសិករខ្នាតតូច។

↓ ប្រឡាយជើងក្អែបនៃប្រព័ន្ធធារាសាស្ត្រស្នាច់ក្នុងស្រុកព្រះនេត្រព្រះ





↑ ច្រកទ្វារទឹកនៃអាងស្តុកទឹកទានកាំ



↑ ដំណើរទស្សនកិច្ចសិក្សាស្វែងយល់អំពីការអនុវត្តការគ្រប់គ្រងសំរាមសំណល់រឹង និងការគ្រប់គ្រងទឹក



↑ ក្រុមពិភាក្សាលើសេចក្តីព្រាងសេចក្តីណែនាំបច្ចេកទេសសម្រាប់ការអនុវត្តមុខងារអប់រំបឋមសិក្សា

# ពីគោលនយោបាយ ទៅការអនុវត្ត៖ ការធ្វើមូលដ្ឋាននីយកម្មនៃការគ្រប់គ្រងវិស័យអប់រំតាមរយៈរដ្ឋបាល ក្រុង ស្រុក ខណ្ឌ

## សមិទ្ធផលសំខាន់ៗ

ការជំរុញសេវាអប់រំមានលក្ខណៈវិមជ្ឈការ និងប្រកបដោយគណនេយ្យភាព៖ កម្មវិធី ISD បានដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកជួយដល់រាជរដ្ឋាភិបាល ក្នុងដំណើការកំណែទម្រង់វិមជ្ឈការវិស័យអប់រំនៅកម្ពុជា។ តាមរយៈកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយលេខាធិការដ្ឋានគ.ជ.អ.ប. ក្រសួងអប់រំ យុវជន និងកីឡា និងកម្មវិធី ISD បានរួមចំណែកជំរុញដល់ការអនុវត្តគោលនយោបាយមុខងារវិស័យអប់រំ នៅថ្នាក់ ក្រុង ស្រុក ខណ្ឌ។ លទ្ធផលជោគជ័យនៃការអនុវត្តសាកល្បង នៅខេត្តបាត់ដំបង បានជំរុញឱ្យរាជរដ្ឋាភិបាលសម្រេចដាក់ឱ្យអនុវត្ត នូវអនុមុខងារចំនួន ៣ ក្នុងវិស័យអប់រំ គឺ៖ មុខងារគ្រប់គ្រងការអប់រំកុមារតូច មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា និងមុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមរយៈអនុក្រឹត្យលេខ ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ។ នេះជាជំហានដ៏សំខាន់មួយសម្រាប់ពង្រឹងដល់ការផ្តល់សេវាវិស័យអប់រំប្រកបដោយគណនេយ្យភាព និងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

**ការសម្របសម្រួល អភិបាលកិច្ច និងគណនេយ្យភាពនៅមូលដ្ឋាន ត្រូវបានពង្រឹង៖** ការធ្វើសមាហរកម្មការិយាល័យអប់រំ យុវជន និងកីឡា ទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាំង ២០៩ គឺជាការលើកកម្ពស់ដល់ការសម្របសម្រួល ភាពជាអ្នកដឹកនាំ និងគណនេយ្យភាពនៅមូលដ្ឋាន ដែលជាការធានាថាមន្ត្រីអប់រំ (ទាំងបុគ្គលិក និងគ្រូបង្រៀន) ទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងផ្នែករដ្ឋបាលទាន់ពេលវេលា។

**សមត្ថភាព និងការដឹកនាំគ្រប់គ្រងក្នុងមូលដ្ឋានមានភាពប្រសើរឡើង៖** ការអនុវត្តសេចក្តីណែនាំបច្ចេកទេសនានា ព្រមទាំងឯកសារបណ្តុះបណ្តាល នឹងធ្វើឱ្យរដ្ឋបាលក្រុង ស្រុក គ្រប់គ្រងមុខងារវិស័យអប់រំ ដែលបានផ្ទេរកាន់តែមានតម្លាភាព សង្គតិភាព និងប្រសិទ្ធភាព។

**លើកកម្ពស់ការចូលរួមនៅមូលដ្ឋាន ឱ្យមានភាពសកម្ម៖** ក្រុមប្រឹក្សា គណៈកម្មការគ្រប់គ្រងសាលា និង សហគមន៍ បានចូលរួមយ៉ាងសកម្មក្នុងការតាមដានត្រួតពិនិត្យការគាំទ្រសាលារៀន ព្រមទាំងជំរុញភាពជាម្ចាស់នៅមូលដ្ឋាន និងការឆ្លើយតបទៅនឹងតម្រូវការសេវាអប់រំ។

**ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំនៅមូលដ្ឋានត្រូវបានពង្រឹង៖** ការផ្ទេរមុខងារវិស័យអប់រំ បានធ្វើឱ្យក្រុង ស្រុក ខណ្ឌ យល់ដឹងកាន់តែច្បាស់អំពីបញ្ហាប្រឈមនានា និងអាចដោះស្រាយបញ្ហាប្រឈមទាំងនោះ ក៏ដូចជាអាចឆ្លើយតបបានកាន់តែមានប្រសិទ្ធភាព ចំពោះតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ដំណើរការសំខាន់ៗ

**ការវាយតម្លៃលើការអនុវត្តសាកល្បងមុខងារ ក្នុងវិស័យអប់រំ៖** បានផ្តល់ការគាំទ្រដល់ក្រសួងអប់រំយុវជន និងកីឡា និងលេខាធិការដ្ឋានគ.ជ.អ.ប ក្នុងការសិក្សាវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរ នៅរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង។ លទ្ធផលនៃការសិក្សានេះត្រូវបានប្រើប្រាស់ជាមូលដ្ឋាន ក្នុងការរៀបចំដាក់ឱ្យអនុវត្តការផ្ទេរមុខងារវិស័យអប់រំក្នុងក្របខណ្ឌទូទាំងប្រទេស។






↑ សិក្ខាសាលាពិគ្រោះយោបល់ស្តីពីសេចក្តីណែនាំបច្ចេកទេសអំពីការផ្ទេរមុខងារក្នុងវិស័យអប់រំ

**ការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តៈ** បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួងអប់រំ យុវជន និងកីឡា និងលេខាធិការដ្ឋានគ.ជ.អ.ប ក្នុងការរៀបចំអនុក្រឹត្យលេខ២១៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡាទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**ការផ្តល់ប្រឹក្សាយោបល់ផ្នែកបច្ចេកទេស និងគោលនយោបាយៈ** បានផ្តល់ប្រឹក្សាយោបល់ដល់ក្រសួងអប់រំយុវជន និងកីឡា លេខាធិការដ្ឋានគ.ជ.អ.ប ក្រសួងមហាផ្ទៃ (តាមរយៈសាលាជាតិរដ្ឋបាលមូលដ្ឋាន) ក្នុងការរៀបចំសេចក្តីណែនាំបច្ចេកទេស[1] ចំនួនប្រាំមួយ (០៦) ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ សិក្ខាសាលាពិគ្រោះយោបល់មួយចំនួនត្រូវបានរៀបចំ ដើម្បីប្រមូលធាតុចូលសម្រាប់បញ្ចប់សេចក្តីណែនាំបច្ចេកទេសទាំងប្រាំមួយនេះ។

**ការអភិវឌ្ឍន៍សមត្ថភាពៈ** បានជួយដល់ក្រសួងអប់រំ យុវជន និងកីឡា លេខាធិការដ្ឋាន គ.ជ.អ.ប. និងក្រសួងមហាផ្ទៃ (តាមរយៈសាលាជាតិរដ្ឋបាលមូលដ្ឋាន) ក្នុងការរៀបចំឯកសារបណ្តុះបណ្តាល ដោយផ្អែកលើគោលការណ៍ណែនាំបច្ចេកទេសទាំងប្រាំមួយ ដើម្បីធានាឱ្យមានការយល់ដឹងដូចគ្នា និងការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**ការសិក្សាទិន្នន័យដើមគ្រាៈ** បានផ្តល់ការគាំទ្របច្ចេកទេសដល់លេខាធិការដ្ឋានគ.ជ.អ.ប. និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងការសិក្សាទិន្នន័យដើមគ្រា អំពីការអនុវត្តការផ្ទេរមុខងារវិស័យអប់រំនៅថ្នាក់ក្រុង ស្រុក ខណ្ឌ មុននឹងដាក់ឱ្យអនុវត្តទូទាំងប្រទេស។ ការសិក្សាទិន្នន័យដើមគ្រានេះ មិនត្រឹមតែជាមូលដ្ឋានសម្រាប់ការវាស់វែងលទ្ធផល និងសមិទ្ធផលជាប្រចាំប៉ុណ្ណោះទេ ប៉ុន្តែការសិក្សានេះ ក៏ជាមូលដ្ឋានសម្រាប់ការវាយតម្លៃអំពីការត្រៀមខ្លួន ព្រមទាំងការកំណត់អំពីតម្រូវការផ្នែកសមត្ថភាព និងធនធានផងដែរ។ ទិន្នន័យសំខាន់ៗទាំងនេះបានតម្រង់ទិសក្នុងការធ្វើផែនការ ការរៀបចំវគ្គបណ្តុះបណ្តាល និងការគាំទ្រដល់ការអនុវត្តសកម្មភាពជាបន្តបន្ទាប់។

## និរន្តរភាព

ការគាំទ្ររបស់កម្មវិធី ISD បានធានានូវនិរន្តរភាពរយៈពេលវែង ក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារវិស័យអប់រំ តាមបែបវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា។ តាមរយៈអនុក្រឹត្យលេខ២១៣ អនក្រ.បក និងការធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡា ទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន ២០៩ បានធានានូវភាពជាម្ចាស់ និងនិរន្តរភាពស្ថាប័ន ក្នុងការអនុវត្តមុខងាររយៈពេលយូរអង្វែង។ សេចក្តីណែនាំបច្ចេកទេសឯកសារបណ្តុះបណ្តាល និងទិន្នន័យដើមគ្រា បានជំរុញឱ្យមានការអភិវឌ្ឍសមត្ថភាព និងការតាមដានត្រួតពិនិត្យលើការអនុវត្តការងារក្នុងលក្ខណៈជាប្រព័ន្ធ។ ការពង្រឹងភាពជាអ្នកដឹកនាំ និងគណនេយ្យភាពនៅមូលដ្ឋាន និងការចូលរួមរបស់សហគមន៍ បានពង្រឹងបន្ថែមទៀតនូវការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមាន និងភាពជាម្ចាស់នៅមូលដ្ឋាន។ ការបែងចែកធនធាន និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលដោយអត់ងាករេ នឹងក្លាយជាយុទ្ធសាស្រ្តគន្លឹះក្នុងការរក្សា និងពង្រីកសមិទ្ធផលទាំងនេះក្រោយពីកម្មវិធី ISD ត្រូវបានបញ្ចប់៕

1 សេចក្តីណែនាំបច្ចេកទេសស្តីពីការគោលការណ៍ បែបបទ នីតិវិធីសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារវិស័យអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

សម្រាប់ភាសាអង់គ្លេស សូមមើលនៅផ្នែកម្ខាងទៀត
Flip over for English version